HKL

កាន់តែទុកចិត្ត កាន់តែចំរើន

ហត្ថាកសិករ លីមីតធីត

HATTHA KAKSEKAR LIMITED

# របាយការណ៍ត្រីមាសទី១

ថ្ងៃទី៣១ ខែមីនា ២០១៩

**Subsidiary of krungsri bank**

A member of MUFG, a global financial group

# មាតិកា

**ទស្សនវិស័យ បេសកកម្ម និងគុណតម្លៃ....................................................................២**
**សមាសភាពក្រុមប្រឹក្សាភិបាល ........................................................................៣**
**ព័ត៌មានហិរញ្ញវត្ថុសង្ខេប...............................................................................៤**
**សារពីប្រធានក្រុមប្រឹក្សាភិបាល........................................................................៥**
**សារពីប្រធានអគ្គនាយក...................................................................................៦**
**ផ្នែកទី ១ : អំពី ហត្ថាកសិករ...........................................................................៧**
១- ព័ត៌មានទូទៅ...........................................................................................៧
២- ដំណើរការធុរកិច្ចសង្ខេប..............................................................................៧
៣- ស្ថានភាពទីផ្សារ.........................................................................................៨
៤- ស្ថានភាពប្រកួតប្រជែង.................................................................................៨
**ផ្នែកទី ២ : ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច .................................................៩**
១- លទ្ធផលប្រតិបត្តិការធុរកិច្ច ដោយរួមបញ្ចូលព័ត៌មានធុរកិច្ចតាមផ្នែក..........................៩
២- ការប្រែប្រួលសំខាន់ៗពាក់ព័ន្ធនឹងប្រតិបត្តិការធុរកិច្ច..........................................៩
៣- រចនាសម្ព័ន្ធចំណូល .................................................................................១០
**ផ្នែកទី ៣ : អភិបាលកិច្ចសាជីវកម្ម...................................................................១១**
១- ភាគហ៊ុនិក .............................................................................................១១
២- រចនាសម្ព័ន្ធក្រុមហ៊ុន ................................................................................១៣
៣- ក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការនានា ......................................................១៣
៤- បុគ្គលិកជាន់ខ្ពស់......................................................................................១៨
**ផ្នែកទី ៤ : ព័ត៌មានអំពីការជួញដូរមូលបត្រ...........................................................២៥**
១- ព័ត៌មានអំពីមូលបត្រកម្មសិទ្ធិ.........................................................................២៥
២- ថ្លៃ និងបរិមាណជួញដូរ ..............................................................................២៥
**ផ្នែកទី ៥ : របាយការណ៍សវនកម្មរបស់សវនករផ្ទៃក្នុងលើការត្រួតពិនិត្យផ្ទៃក្នុង ....................២៦**
១- កម្មវត្ថុសវនកម្ម.......................................................................................២៦
២- វិសាលភាពសវនកម្ម...................................................................................២៦
៣- សង្ខេបរបាយការណ៍....................................................................................២៧
**ផ្នែកទី ៦ : របាយការណ៍ហិរញ្ញវត្ថុដែលបានពិនិត្យឡើងវិញដោយសវនករឯករាជ្យ ..................៣០**
**ផ្នែកទី ៧ : ព័ត៌មានអំពីប្រតិបត្តិការជាមួយភាគីជាប់ពាក់ព័ន្ធ ......................................៣៧**
**ផ្នែកទី ៨ : ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង ..........................................៣៨**
១- ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ .........................................................................៣៨
២- កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ .......................................................៣៩
៣- ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល ......................................................៣៩
៤- ផលប៉ះពាល់នៃការប្តូររូបិយបណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ ...................................៣៩
៥- ផលប៉ះពាល់នៃអតិផរណា ............................................................................៣៩

## តារាងក្នុងការប្រើប្រាស់ពាក្យ

| ពាក្យពេញ និងផ្លូវការ | ពាក្យប្រើប្រាស់ |
|---|---|
| គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុហត្ថាកសិករ លីមីតធីត | ហត្ថាកសិករ |
| បុគ្គលបោះផ្សាយ | ហត្ថាកសិករ ឬ HKL |

## ចក្ខុវិស័យ និងបេសកកម្ម

| | |
|---|---|
| ចក្ខុវិស័យ | ជាគ្រឹះស្ថានហិរញ្ញវត្ថុដែលទទួលបានការកោតសរសើរខ្ពស់ និងជាជម្រើសដែលអតិថិជនពេញចិត្ត តាមរយៈបុគ្គលិកប្រកបដោយវិជ្ជាជីវៈ។ |
| បេសកកម្ម | យើងផ្តល់ជូនអតិថិជននូវដំណោះស្រាយហិរញ្ញវត្ថុ ដែលគួរឱ្យជឿទុកចិត្ត ងាយស្រួល និងប្រកបដោយភាពច្នៃប្រឌិត តាមរយៈបច្ចេកវិទ្យាឌីជីថល ដែលនាំមកនូវបទពិសោធល្អៗដល់អតិថិជន។ យើងប្តេជ្ញាចូលរួមចំណែកដល់ការរីកចម្រើនរបស់អតិថិជន និងសង្គម ប្រកបដោយចេរភាព។ |

## តម្លៃស្នូល

| | |
|---|---|
| ស្មោះត្រង់ | យើងប្តេជ្ញាធ្វើអ្វីដែលល្អ ប្រកបដោយភាពស្មោះត្រង់ ត្រឹមត្រូវ តម្លាភាព ទទួលខុសត្រូវ និងវិជ្ជាជីវៈ។ |
| ឧត្តមភាព | យើងប្តេជ្ញាធ្វើការងារប្រកបដោយឧត្តមភាពក្នុងកម្រិតបទដ្ឋានកាន់តែខ្ពស់ ហើយយើងចាប់យកការផ្លាស់ប្តូរ និងភាពច្នៃប្រឌិត ផ្នែកបច្ចេកវិទ្យា ដើម្បីក្លាយជាអ្នកនាំមុខគេនៅក្នុងទីផ្សារ។ |
| គាំពារ | យើងជួយ និងយកចិត្តទុកដាក់ចំពោះអតិថិជន តាមរយៈការធ្វើការរួមគ្នាដើម្បីកសាងអនាគត ឱ្យកាន់តែប្រសើរ។ |
| ថាមវន្ត | យើងមានសុទិដ្ឋិនិយម និងសេចក្តីស្វាហាប់ដើម្បីដឹកនាំ និងធ្វើការរួមគ្នាក្នុងបរិយាកាសបើកទូលាយដើម្បីសម្រេចគោលដៅរបស់យើង។ |
| សាមញ្ញ | យើងធ្វើអ្វីៗឱ្យមានលក្ខណៈសាមញ្ញ ងាយស្រួល និងសមស្របសម្រាប់អតិថិជនដោយផ្អែកលើតម្រូវការរបស់ពួកគាត់ជាអទិភាព។ |

# សមាសភាពក្រុមប្រឹក្សាភិបាល



**លោក Sudargo Harsono**
ប្រធានក្រុមប្រឹក្សាភិបាល



**លោក Piyasak Ukritnukun**
សមាជិក



**លោក ហួត អៀងតុង**
សមាជិក



**កញ្ញា Duangdao Wongpanitkrit**
សមាជិក



**លោក Rohit Khanna**
សមាជិក



**លោក Chandrashekar S.K.**
សមាជិក



លោក ឡូញ ហៃ
សមាជិកឯករាជ្យ



តាល់ ណៃអ៊ីម
សមាជិកឯករាជ្យ



លោក ឌី ជាវុឌ្ឍ
សមាជិកឯករាជ្យ

| បរិយាយ | | ត្រីមាសទី១<br>ឆ្នាំ -២០១៨ | ត្រីមាសទី១<br>ឆ្នាំសារពើពន្ធបច្ចុប្បន្ន |
|---|---|---|---|
| ស្ថានភាពហិរញ្ញវត្ថុ | | | |
| ទ្រព្យសកម្មសរុប (លានរៀល) | | ៣,០៩៦,២៧៧ | ៣,៩៤៧,៨៩២ |
| បំណុលសរុប (លានរៀល) | | ២,៦៧១,១៥៥ | ៣,២៥៦,២៦៨ |
| មូលធនសរុប (លានរៀល) | | ៤២៥,១២២ | ៦៩១,៦២៤ |
| លទ្ធផលហិរញ្ញវត្ថុ | | | |
| ចំណូលសរុប (លានរៀល) | | ១០៤,៨៦៣ | ១៣៣,០៨៥ |
| ចំណេញមុនបង់ពន្ធ (លានរៀល) | | ២០,២៥២ | ៣១,០៦២ |
| សរុបប្រាក់ចំណេញក្នុងគ្រា (លានរៀល) | | ១៤,២៦៥ | ២៣,៩៤១ |
| អនុបាតហិរញ្ញវត្ថុ | | | |
| អនុបាតសាធនភាព (ភាគរយ) | | ១៧.៧២ | ២០.៥១ |
| អនុបាតសន្ទនីយភាព (ភាគរយ) | | ១៣៨.៨៥ | ១០០.៤៩ |
| អនុបាតចំណេញភាព | ផលចំណេញក្នុងមួយឯកតាទ្រព្យសកម្ម (ភាគរយ) ជាប្រចាំឆ្នាំ | ១.៨៤ | ២.៤៣ |
| | ផលចំណេញក្នុងមួយឯកតាមូលធន (ភាគរយ) ជាប្រចាំឆ្នាំ | ១៣.៤២ | ១៣.៨៥ |
| | ចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (រៀល) 1/ | ១៣,៤៧៣ | ២០,០៩៩ |
| ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (ប្រសិនមាន) | | គ្មាន | គ្មាន |

1/ ប្រាក់ចំណេញក្នុងគ្រា ចែកចំនួនមូលបត្របំណុល ។ប្រាក់ចំណេញក្នុងគ្រាមិនរួមបញ្ចូល ចំណូលបន្ទាប់បន្សំផ្សេងៗ។

## សារពីប្រធានក្រុមប្រឹក្សាភិបាល

ខ្ញុំមានសេចក្ដីរីករាយក្នុងការផ្ញើសារទៅកាន់វិនិយោគិនរបស់យើងជាលើកដំបូងតាមរយៈរបាយការណ៍ទៅកាន់គណៈកម្មការមូលបត្រកម្ពុជា (គ.ម.ក) នេះ។ ក្នុងនាមជាអ្នកបោះផ្សាយមូលបត្របំណុលសាជីវកម្មដំបូងគេនៅកម្ពុជា ចាប់ពីខែវិច្ឆិកាឆ្នាំ ២០១៨ ជាមួយចំនួន ទឹកប្រាក់ ១២០ ពាន់លានរៀល (៣០ លានដុល្លារ) ហត្ថាកសិករ មានមោទនភាពដែលខ្លួនជាអ្នកចាប់ផ្ដើមលើកកម្ពស់ទីផ្សារមូលធនបំណុលនៅកម្ពុជា និង លើកស្ទួយរូបិយប័ណ្ណប្រាក់រៀល។ ក្នុងនាមជាបុត្រសម្ព័ន្ធនៃធនាគារ Ayudhya (ដែលត្រូវបានគេស្គាល់ថា Krungsri) និងជាសមាជិករបស់ MUFG ក្រុមហ៊ុនហត្ថាកសិករ (HKL) បានបញ្ចប់ឆ្នាំសារពើពន្ធ ២០១៨ ជាមួយនឹងសមិទ្ធផលដ៏រឹងមាំ។ ជាលទ្ធផលនៃការអនុវត្តយុទ្ធសាស្ត្រដែលមានប្រសិទ្ធភាពនិងការរៀបចំរចនាសម្ព័ន្ធខាងក្នុង យើងបានបង្កើនផលប័ត្រឥណទានរហូតដល់ ៧៥៧ លានដុល្លារអាមេរិ ដែលកំណើននេះបានកើនឡើង ៣១% ពីឆ្នាំ ២០១៧។ ឥណទានមិនដំណើរការរបស់យើងមានកម្រិត ០.៦៨% ដែលទាបជាងមធ្យមភាគទីផ្សារ។ ការចំណាយលើថ្លៃដើមការប្រាក់ បានប្រសើរឡើងត្រឹម ៧.១៦% ពី ៧.៤៧% នៅឆ្នាំ ២០១៧។ ប្រាក់ចំណូលសុទ្ធបានកើនឡើងដល់ ២០.៨ លានដុល្លារ ស្មើនឹងកំណើន ៣៥% ពីឆ្នាំ ២០១៧។

លើសពីនេះទៅទៀត ហត្ថាកសិករ បានទទួលការអនុម័ត ពីនិយតករ នៅខែសីហាឆ្នាំ ២០១៨ ដើម្បីបង្កើនដើមទុន របស់ខ្លួនចំនួន ៣០ លានដុល្លារអាមេរិកបន្ថែមពី Krungsri ដែលធ្វើឱ្យដើមទុនចុះបញ្ជីរបស់ខ្លួនកើនឡើងដល់ ៧៥ លានដុល្លាអាមេរិក។ ការបង្កើនដើមទុន នេះបានបង្ហាញពីការប្ដេជ្ញាចិត្តដ៏រឹងមាំរបស់ Krungsri ចំពោះហត្ថាកសិករ និងសេដ្ឋកិច្ចកម្ពុជាទាំងមូល។ ចំនួនដើមទុន គឺលើសពីតម្រូវការបទបញ្ញត្តិដើមទុនសម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួល ប្រាក់បញ្ញើ និងបានបំពេញតាមលក្ខខណ្ឌដើមទុនរបស់ ធនាគារពាណិជ្ជ។

ក្នុងឆ្នាំ២០១៩ ដោយមានទំនុកចិត្តលើការបន្តរីកចម្រើន ហត្ថាកសិករ កំពុងជំរុញស្តង់ដារបស់ខ្លួនឱ្យឆ្ពោះទៅរកស្តង់ដារធនាគារ។ ជាលទ្ធផលនៅក្នុងត្រីមាសទី១ ឆ្នាំ ២០១៩ គឺទទួលបានលទ្ធផលល្អ។ គិតត្រឹមថ្ងៃទី៣១ ខែមីនាឆ្នាំ ២០១៩ ទ្រព្យសកម្មសរុបរបស់យើងមានចំនួនជាង ៩៨៣ លានដុល្លារអាមេរិក ផលប័ត្រឥណទានមានចំនួន ៨២៥ លានដុល្លារអាមេរិក និងកំពុងបម្រើអតិថិជនសរុបចំនួនជាង ១៣៧,១២៤ នាក់ ទូទាំងប្រទេសកម្ពុជា។ ឥណទានមិនដំណើរការ៣០ថ្ងៃ ត្រូវបានគ្រប់គ្រងយ៉ាងល្អនៅកម្រិត ០.៥៦%។ ប្រាក់បញ្ញើសន្សំបានកើនឡើងដល់ ៥១៥ លានដុល្លារអាមេរិក។ ប្រាក់ចំណេញសុទ្ធបាន កើនឡើង ៦ លានដុល្លារអាមេរិក និងបុគ្គលិករបស់យើងមានចំនួន ៣,៨២៩ នាក់បន្ត ដែលធ្វើឱ្យហត្ថាកសិករ កាន់តែប្រសើរឡើងក្នុងការផ្តល់ជូននូវសេវាកម្មអតិថិជននៅទូទាំងបណ្តាញសាខារបស់យើង។

ខ្ញុំសង្ឃឹមជឿជាក់ថាឆ្នាំ ២០១៩ យើងនឹងនៅតែបន្តប្តេជ្ញាចិត្តក្នុងការផ្តល់នូវដំណោះស្រាយហិរញ្ញវត្ថុ ប្រកបដោយភាពជឿជាក់ ងាយស្រួល និងប្រកបដោយភាពច្នៃប្រឌិត ដល់អតិថិជនដើម្បីឆ្លើយតបទៅនឹងតម្រូវការ និងការរីកចម្រើនប្រកបដោយនិរន្តរភាព។

**លោក Sudargo Harsono**
**ប្រធានក្រុមប្រឹក្សាភិបាល**

# សារពីប្រធានអគ្គនាយក

“ដោយមានការប្តេជ្ញាចិត្តយ៉ាងមុតមាំពីបុគ្គលិក និងគណៈគ្រប់គ្រង ហត្ថាកសិករ ដែលមានម្ចាស់ភាគហ៊ុន ជាធនាគារ Ayudhya ជាធនាគារពាណិជ្ជឈានមុខគេមួយនៅក្នុងប្រទេសថៃ និងជាសមាជិករបស់ MUFG។ ហត្ថាកសិករ ត្រៀមខ្លួនផ្តល់ជូននូវសេវាកម្មនិងផលិតផលហិរញ្ញវត្ថុប្រកបដោយនិរន្តភាព ជាមួយនឹង ទស្សនវិស័យឌីជីថលកាន់តែទូលំទូលាយខណៈពេលដែលផ្តល់នូវដំណោះស្រាយហិរញ្ញវត្ថុ ប្រកបដោយភាពជឿ ទុកចិត្ត ងាយស្រួល និងប្រកបដោយភាពច្នៃប្រឌិត ដែលនាំមកនូវបទ ពិសោធន៍ល្អដល់អតិថិជន។ “

គិតត្រឹមខែមីនាឆ្នាំ ២០១៩ អតិថិឥណទានសរុបរបស់យើងចំនួនជាង ១៣៧,១២៤នាក់ អតិថិជនដាក់ប្រាក់បញ្ញើសន្សំចំនួនជាង ២១០,០១៣នាក់ និងអតិថិជនប្រើប្រាស់ប័ណ្ណអេធិអឹមចំនួនជាង ៤៧,០២៧នាក់។ ផលប័ត្រឥណទាន បានឈានដល់ ៨២៥ លានដុល្លារអាមេរិក ស្របពេលទទួលបានកំណើននៃប្រាក់ចំណេញសុទ្ធគួរឱ្យកត់សម្គាល់គឺ ៦ លានដុល្លារអាមេរិក។ ចំនួនប្រាក់បញ្ញើសន្សំ បានកើនឡើងដល់ ៥១៥ លានដុល្លារអាមេរិក ដែលបង្ហាញពីទំនុកចិត្តខ្ពស់បំផុតពីអតិថិជន និងសាធារណជនមកកាន់ហត្ថាកសិករ ។

ប្រតិបត្តិការរបស់ហត្ថាកសិករត្រូវបានពង្រីកដល់ ១៧៨សាខា ជាមួយនឹងម៉ាស៊ីន ATM ចំនួន១២៩ នៅទូទាំងប្រទេស។ បុគ្គលិករបស់យើងមានចំនួនសរុប ៣,៨២៩នាក់ កំពុងផ្តល់ជូននូវ សេវាកម្មហិរញ្ញវត្ថុ ដ៏ល្អបំផុតតាមរយៈបណ្តាញសាខាយ៉ាងធំទូលំទូលាយទូទាំងផ្ទៃប្រទេស។

នៅក្នុងផ្នែកឌីជីថល ហត្ថាកសិករនៅតែបន្តនាំយកបច្ចេកវិទ្យាជឿនលឿនថ្មីៗ និងទាញជាប្រយោជន៍សម្រាប់គ្រប់សកម្មភាពប្រតិបត្តិការទាំងអស់ ដើម្បីឆ្លើយតបតម្រូវការរបស់អតិថិជនឱ្យទទួលបាននិរន្តរភាពក្នុងសម័យឌីជីថលនេះ។ យើងបន្តពង្រីកប្រព័ន្ធធានាគារចល័តទាំង តាមរយៈទូរស័ព្ទ និងInternet ដើម្បីបម្រើអតិថិជន របស់យើងឱ្យបានកាន់តែប្រសើរ ឡើងតាមរយៈក្រុមការងារ ដែលមានបទពិសោធន៍ខ្ពស់។ មកដល់ពេលបច្ចុប្បន្នអតិថិជនប្រើប្រាស់ ប្រព័ន្ធធានាគារចល័តទាំង តាមរយៈទូរស័ព្ទ និងInternetមានចំនួនជាង ៧,៥១៧។ ហត្ថាកសិករខិតខំផ្តល់ជូននូវសេវាកម្មហិរញ្ញវត្ថុឈានមុខគេមួយ ដែលមានភាពងាយស្រួល និងទុកចិត្តបានដល់អតិថិជន។ នៅខែឧសភា ឆ្នាំ ២០១៨ ហត្ថាកសិករ ទទួលត្រូវបានការចាត់ចំណាត់ថ្នាក់ «BBB+» ពីភ្នាក់ងារវាយតម្លៃអន្តរជាតិ TRIS បានបញ្ជាក់ពីប្រតិបត្តិ ការមានស្ថេរភាពជាមួយនឹងជំហររឹងមាំក្នុងទីផ្សារកម្ពុជា។ ចំណុចវាយតម្លៃរួមមានដូចជាបណ្តាញសាខាទូទាំងប្រទេសភាពចម្រុះ នៃប្រភេទអតិថិជន ប្រព័ន្ធគ្រប់គ្រងហានិភ័យល្អ, ការគ្រប់គ្រងហិរញ្ញវត្ថុនិងសាច់ប្រាក់រឹងមាំ។

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់គណៈគ្រប់គ្រងនិងបុគ្គលិកដែលបានប្តេជ្ញាចិត្ត និងចូលរួមជាមួយសមិទ្ធផលដ៏អស្ចារ្យនេះ។ ខ្ញុំសូមកោតសរសើរចំពោះទំនុកចិត្តនិងការគាំទ្រជាបន្តបន្ទាប់ដែលផ្តល់ដោយអតិថិជន ដៃគូនិងសាធារណជន ហើយខ្ញុំសង្ឃឹមនិងជឿជាក់ថានឹងផ្តល់ជូននូវសេវាកម្មហិរញ្ញវត្ថុស្តង់ដា ខ្ពស់បំផុត ក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខនេះ។

លោក ហួត អៀងគុង
ប្រធានអគ្គនាយក

# ផ្នែកទី ១ : ព័ត៌មានពីហត្ថាកសិករ

## ១-ព័ត៌មានទូទៅ

| | |
|---|---|
| ឈ្មោះក្រុមហ៊ុនជាអក្សរខ្មែរ | ហត្ថាកសិករ លីមីតធីត |
| ឈ្មោះជាអក្សរឡាតាំង | Hattha Kaksekar Limited |
| អក្សរកូដ | HKL |
| អាសយដ្ឋាន | អគារលេខ ៦០៦ ផ្លូវ២៧១ ភូមិសន្សំកុសល ៣ សង្កាត់បឹងទំពន់ទី១ ខណ្ឌមានជ័យ រាជធានីភ្នំពេញ |
| លេខទូរស័ព្ទ | ០២៣ ៩៩៤ ៣០៤ |
| គេហទំព័រ | www.hkl.com.kh |
| អ៊ីម៉ែល | info@hkl.com.kh |
| លេខវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម | ០០០០៥៣៥៥ (ថ្ងៃទី០៣ ខែមេសា ឆ្នាំ២០០១) |
| លេខអាជ្ញាបណ្ណអាជីវកម្ម | ម.ហ ០២-១២/០៦/១១/០១ ចេញដោយ: ធនាគារជាតិ នៃ កម្ពុជា កាលបរិច្ឆេទ: ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៧ |
| **សេចក្តីសម្រេចអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មាន** | លេខ ១៦៥/១៨គ.ម.ក. កាលបរិច្ឆេទ: ថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៨ |
| តំណាងHKLដោយ | លោកហួត អៀងតុង |

## ២-ដំណើរការធុរកិច្ចសង្ខេប

ហត្ថាកសិករ គឺជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើសន្សំធំមួយ ទទួលបានអាជ្ញាប័ណ្ណ ពី ធនាគារជាតិនៃកម្ពុជា និងបានធ្វើប្រតិបត្តិការជាង ២៥ឆ្នាំ មកហើយ។ ហត្ថាកសិករ បាននឹងកំពុងផ្តល់សេវាកម្មហិរញ្ញវត្ថុយ៉ាងសម្បូរបែបដល់អតិថិជនដូចជា៖ សេវាឥណទាន សេវាប្រាក់បញ្ញើសន្សំ សេវាផ្ទេរប្រាក់ក្នុងស្រុក សេវាអេធីអឹម សេវាធនាគារចល័ត សេវាបើកប្រាក់បៀវត្ស និងជាអ្នកណែនាំលក់សេវាធានារ៉ាប់រងផងដែរ តាមរយៈសាខាចំនួន ១៧៨ និងម៉ាស៊ីនអេធីអឹមចំនួន ១២៩ ទីតាំងនៅទូទាំងប្រទេស។ គិតត្រឹមខែមីនា ឆ្នាំ ២០១៩ សមតុល្យប្រាក់បញ្ញើសន្សំរបស់ហត្ថាកសិករ មានចំនួនជាង ៥១៥ លានដុល្លារអាមេរិក ជាមួយនឹងចំនួនអតិថិជន ប្រាក់បញ្ញើសន្សំជាង ២១០,០១៣ នាក់ ជាមួយផលប័ត្រឥណទានសរុបមាន ចំនួនប្រមាណ ៨២៥ លានដុល្លារអាមេរិកដែលបម្រើអតិថិជន ចំនួនជាង ១៣៧,១២៤ នាក់។ បច្ចុប្បន្ន ហត្ថាកសិករ គឺជាបុត្រសម្ព័ន្ធរបស់ ធនាគារ Krungsri ដែលជាធនាគារពាណិជ្ជធំជាងគេលំដាប់ទី ៥ នៅព្រះរាជាណាចក្រថៃឡង់ និងជាសមាជិករបស់សម្ព័ន្ធហិរញ្ញវត្ថុអន្តរជាតិ Mitsubishi UFJ Financial Group (MUFG) ដែលជាសម្ព័ន្ធធនាគារធំជាងគេបំផុតនៅប្រទេសជប៉ុន ព្រមទាំងជាសម្ព័ន្ធសេវាហិរញ្ញវត្ថុដ៏ធំមួយក្នុងចំណោម សម្ព័ន្ធហិរញ្ញវត្ថុ ធំជាងគេលើសកលលោក។

### ៣. ស្ថានភាពទីផ្សារ

ក្នុងរយៈពេលជាង២ទសវត្សរ៍ចុងក្រោយនេះ សេដ្ឋ កិច្ចប្រទេសកម្ពុជាមានភាពរីកចម្រើនប្រកបដោយស្ថេរភាព និងសម្រេច បាននូវកំណើនសេដ្ឋកិច្ចក្នុងរង្វង់ ៧% ជាបន្តបន្ទាប់។ ហើយការរីកលូតលាស់ដ៏រឹងមាំនៃសេដ្ឋកិច្ចគឺបានគាំទ្រ ជាចម្បងដោយ សារកំណើនខ្ពស់នៅក្នុងវិស័យកសិកម្ម វិស័យទេសចរណ៍ និងការបន្តកើនឡើងនៃការនាំចេញរបស់ វិស័យវាយនភ័ណ្ឌ ព្រមទាំង វិស័យសំណង់និងអចលនទ្រព្យ។

ចំណែកវិស័យហិរញ្ញវត្ថុ និងធនាគារវិញ ក៏មានការរីកចម្រើនគួរឱ្យគាត់សម្គាល់ដែរ ដោយគិតត្រឹមខែ ធ្នូ ឆ្នាំ ២០១៨ គ្រឹះស្ថានធនាគារពាណិជ្ជមានចំនួន ៤៣ ធនាគារឯកទេសចំនួន ១៤ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើសន្សំពីសាធារណចំនួន០៦ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន ៧៣ និង ប្រតិបត្តិករឥណទាននៅតាមជនបទជាច្រើនទៀត។ ទោះបីជាប្រទេសកម្ពុជាមានគ្រឹះស្ថានធនាគារ និងមីក្រូហិរញ្ញវត្ថុច្រើនយ៉ាងនេះក្តី ក៏នៅមានប្រជាពលរដ្ឋកម្ពុជាប្រមាណ ២៩% មិនទាន់បានប្រើប្រាស់សេវាហិរញ្ញវត្ថុក្នុងប្រព័ន្ធនៅឡើយ (FinScope Consumer Survey, Cambodia 2015)។

### ៤. ស្ថានភាពប្រកួតប្រជែង

ការប្រកួតប្រជែងនៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុនៅនៅក្នុងត្រីមាសទី១ ឆ្នាំ ២០១៩ នេះ មិនមានអ្វីប្រែប្រួលគួរឱ្យកត់សម្គាល់នោះទេ ប៉ុន្តែយើងឃើញមានការប្រែប្រួលមួយចំនួនតូចទៅលើអត្រាការប្រាក់ និងកម្រៃសេវាឥណទានដោយបាន បង្កើនកម្រៃសេវាឥណទានខ្នាតតូចបំផុត និងបញ្ចុះកម្រៃសេវាឥណទានខ្នាតមធ្យម។ សម្រាប់ការប្រែប្រួលកម្រៃសេវានេះ មិនមានផលប៉ះពាល់ណាមួយដល់ដំណើរការធុរកិច្ចរបស់ហត្ថាកសិករនោះទេ។

# ផ្នែកទី ២ : ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច

## ១. លទ្ធផលប្រតិបត្តិការធុរកិច្ច ដោយរួមបញ្ចូលធុរកិច្ចតាមផ្នែក (នាដំណាច់ខែមីនា ២០១៩)

| លទ្ធផលសម្រេចបានសំខាន់ៗ | ផែនការ | លទ្ធផលសម្រេចបាន |
|---|---|---|
| **ផ្នែកសេវាឥណទាន** | | |
| ចំនួនគណនីសេវាឥណទាន | ១៤៤,៩៧២ | ១៤៨,៩៩៦ |
| ឥណទាននៅក្នុងដៃអតិថិជន (ពាន់ដុល្លារអាមេរិក) | ៧៨៧,២៨៤ | ៨២៥,៤៨៨ |
| **ផ្នែកសេវាប្រាក់បញ្ញើសន្សំ** | | |
| ចំនួនគណនីសេវាប្រាក់បញ្ញើសន្សំ | ២៤៩,៩២៩ | ២៤១,២២៧ |
| សមតុលប្រាក់បញ្ញើសន្សំ (ពាន់ដុល្លារអាមេរិក) | ៤៦៥,១៧៧ | ៥១៥,៤៦៤ |
| **ផ្នែកសេវាកម្មផ្សេងៗទៀត** | | |
| ចំនួនអ្នកប្រើប្រាស់កាតអេធីអឹម | ៥០,៤៤១ | ៤៧,០២៧ |
| ចំនួនអ្នកប្រើប្រាស់កាតសេវាធនាគារចល័ត | ៧,៦០៣ | ៧,៥១៧ |
| ការណែនាំភ្ញៀវឱ្យប្រើប្រាស់សេវាធានារ៉ាប់រងខ្នាតតូច (ដុល្លារអាមេរិក) | ១៥១,៨៦៥ | ១២៦,៩៩៧ |
| ការណែនាំភ្ញៀវឱ្យប្រើប្រាស់សេវាធានារ៉ាប់រងអាយុជីវិតឥណទាន (ដុល្លារអាមេរិក) | ៣៩៦,១៨៩ | ១,១១៤,៦៦៨ |
| **ផ្នែកប្រតិបត្តិការសំខាន់ផ្សេងៗទៀត** | | |
| ចំនួនការិយាល័យ | ១៧៨ | ១៧៨ |
| ចំនួនអេធីអឹម | ១២៩ | ១២៩ |
| ចំនួនបុគ្គលិក | ៣,៩៧០ | ៣,៨២៩ |

## ២. ការប្រែប្រួលសំខាន់ៗពាក់ព័ន្ធនឹងប្រតិបត្តិការធុរកិច្ច

ដើម្បីបំពេញតម្រូវការរបស់អតិថិជន នៅក្នុងត្រីមាសទីមួយនេះ ហត្ថាកសិករ បាននឹងកំពុងបង្កើតផលិតផលថ្មីៗដូចជា ឥណទានរហ័សជាដើម។ ឥណទានប្រភេទនេះ អាចជួយសម្រួលដល់អតិថិជន ដែលមានតម្រូវការបង់រំលស់លើសម្ភារប្រើប្រាស់ផ្ទាល់ខ្លួនផ្សេងៗ។ ក្រៅពីនេះហត្ថាកសិករ បាននឹងកំពុងកែសម្រួលនូវលក្ខខណ្ឌផលិតផល ដើម្បីបំពេញតម្រូវការអតិថិជន និងដើម្បីប្រកួតប្រជែង នៅលើទីផ្សារបានកាន់តែប្រសើរដូចជា ឥណទានកាតគ្រី ផលិតផលប្រាក់បញ្ញើសន្សំ សេវាកម្មធនាគារចល័ត និងសេវាកម្ម អេធីអឹមជាដើម។

### ៣-រចនាសម្ព័ន្ធចំណូល

| ល.រ | ប្រភពចំណូល | ត្រីមាសទី១ ឆ្នាំ -២០១៧ | | ត្រីមាសទី១ ឆ្នាំ -២០១៨ | | ត្រីមាសទី១ ឆ្នាំសារពើពន្ធបច្ចុប្បន្ន | |
|---|---|---|---|---|---|---|---|
| | | ចំនួនទឹកប្រាក់ (ពាន់រៀល) | ភាគរយ | ចំនួនទឹកប្រាក់ (លានរៀល) | ភាគរយ | ចំនួនទឹកប្រាក់ (លានរៀល) | ភាគរយ |
| ១ | ចំណូលការប្រាក់ | | | ១០១,៦៧៦ | ៩៦.៩៦ | ១២៧,៤៨៦ | ៩៥.៧៩ |
| ២ | ចំណូលផ្សេងៗ | | | ៣,១៨៧ | ៣.០៤ | ៥,៥៩៩ | ៤.២១ |
| ចំណូលសរុប | | | | ១០៤,៨៦៣ | | ១៣៣,០៨៥ | |

*តួលេខត្រីមាសទី១ ឆ្នាំ ២០១៧ ស្ថិតនៅក្នុងបទដ្ឋានផ្សេងមិនអាចប្រៀបធៀបបាន។

# ផ្នែកទី ៣ : អភិបាលកិច្ចសាជីវកម្ម

**១-ភាគហ៊ុនិក**

**ក-ការការពារសិទ្ធិភាគហ៊ុនិក**

ភាគហ៊ុនិកជាអ្នកជ្រើសរើស និងតែងតាំងក្រុមប្រឹក្សាភិបាល។ ភាគហ៊ុនិកទទួលបានការការពារដោយ ក្រុមប្រឹក្សាភិបាល។

**ខ-ការបែងចែកប្រភេទភាគហ៊ុនិក** ( គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ ២០១៩ )

| បរិយាយ | សញ្ជាតិ | ប្រភេទភាគហ៊ុនិក | ចំនួនភាគហ៊ុនិក | ចំនួនមូលបត្រ | ភាគរយ |
|---|---|---|---|---|---|
| តិចជាង ០៥ % | សញ្ជាតិខ្មែរ | រូបវន្តបុគ្គល | គ្មាន | គ្មាន | គ្មាន |
| | | នីតិបុគ្គល | គ្មាន | គ្មាន | គ្មាន |
| | មិនមាន សញ្ជាតិខ្មែរ | រូបវន្តបុគ្គល | គ្មាន | គ្មាន | គ្មាន |
| | | នីតិបុគ្គល | គ្មាន | គ្មាន | គ្មាន |
| ចាប់ពី ០៥% ដល់តិចជាង ៣០ % | សញ្ជាតិខ្មែរ | រូបវន្តបុគ្គល | គ្មាន | គ្មាន | គ្មាន |
| | | នីតិបុគ្គល | គ្មាន | គ្មាន | គ្មាន |
| | មិនមាន សញ្ជាតិខ្មែរ | រូបវន្តបុគ្គល | គ្មាន | គ្មាន | គ្មាន |
| | | នីតិបុគ្គល | គ្មាន | គ្មាន | គ្មាន |
| ចាប់ពី ៣០ % ឡើងទៅ | សញ្ជាតិខ្មែរ | រូបវន្តបុគ្គល | គ្មាន | គ្មាន | គ្មាន |
| | | នីតិបុគ្គល | គ្មាន | គ្មាន | គ្មាន |
| | មិនមាន សញ្ជាតិខ្មែរ | រូបវន្តបុគ្គល | គ្មាន | គ្មាន | គ្មាន |
| | | នីតិបុគ្គល | ១ | ៧៥,០០០,០០០ | ១០០% |

**គ-អភិបាល បុគ្គលិកជាន់ខ្ពស់ និងនិយោជិតដែលកាន់កាប់មូលបត្រកម្មសិទ្ធិរបស់បុគ្គលបោះផ្សាយ**

| ភាគហ៊ុនិក | ចំនួនភាគហ៊ុនិក | ចំនួនមូលបត្រ | ភាគរយ |
|---|---|---|---|
| អភិបាល | គ្មាន | គ្មាន | គ្មាន |
| បុគ្គលិកជាន់ខ្ពស់ | គ្មាន | គ្មាន | គ្មាន |
| និយោជិត | គ្មាន | គ្មាន | គ្មាន |
| សរុប | គ្មាន | គ្មាន | គ្មាន |

**ឃ-ការផ្លាស់ប្តូរភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើន និងភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់ ដោយបញ្ជាក់អំពីអត្តសញ្ញាណគិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ ២០១៩៖** ពុំមានការផ្លាស់ ប្តូរភាគហ៊ុនិកទេ។

**ង-អត្តសញ្ញាណភាគហ៊ុនិកកាន់កាប់ភាគហ៊ុនចាប់ពី ០៥% (ប្រាំ)ឡើងទៅ ស្ថិតក្នុងស្ថានភាពអសាធនភាព គិតត្រឹម ថ្ងៃទី៣១ ខែមីនា ឆ្នាំ ២០១៩៖** គ្មាន។

**ច-កិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិក**

| ល.រ | កាលបរិច្ឆេទ | ប្រភេទកិច្ចប្រជុំ | របៀបវារៈ | សេចក្តីសម្រេច |
|---|---|---|---|---|
| ១ | ០៨ មករា ២០១៩ | សេចក្តីសម្រេចជាលាយលក្ខណ៍អក្សរ | តែងតាំងស្នងការ គណនេយ្យឯករាជ្យ | អនុម័ត |
| ២ | ០៨ មករា ២០១៩ | សេចក្តីសម្រេចជាលាយលក្ខណ៍អក្សរ | ផ្លាស់ប្តូរសមាសភាព ក្រុមប្រឹក្សាភិបាល ២នាក់ | អនុម័ត |

**ឆ-គោលនយោបាយភាគលាភ**

ឆ-១-គោលនយោបាយភាគលាភរបស់HKLប្រាក់ចំណេញ សុទ្ធទាំងអស់ត្រូវបានបញ្ចូលទៅក្នុងខ្ទង់ ប្រាក់ចំណេញ រក្សា ទុក។

ឆ-២-ព័ត៌មានប្រវត្តិការបែងចែកភាគលាភក្នុងរយៈពេល ០៣ (បី) ត្រីមាសចុងក្រោយ (ប្រសិនមាន)

| ពិពណ៌នាលម្អិតអំពីការបែងចែងភាគលាភ | ត្រីមាសទី២ | ត្រីមាសទី១ | ត្រីមាសទី១ឆ្នាំសារពើពន្ធបច្ចុប្បន្ន |
|---|---|---|---|
| ចំណេញសុទ្ធ | គ្មាន | គ្មាន | គ្មាន |
| ភាគលាភជាសាច់ប្រាក់សរុប | គ្មាន | គ្មាន | គ្មាន |
| ភាគលាភជាមូលបត្រកម្មសិទ្ធិសរុប | គ្មាន | គ្មាន | គ្មាន |
| ភាគលាភផ្សេងទៀត | គ្មាន | គ្មាន | គ្មាន |
| អនុបាតចំណាយភាគលាភ (%) | គ្មាន | គ្មាន | គ្មាន |
| ទិន្នផលភាគលាភ (%) | គ្មាន | គ្មាន | គ្មាន |
| ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ | គ្មាន | គ្មាន | គ្មាន |

## ២- រចនាសម្ព័ន្ធក្រុមហ៊ុន (គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ ២០១៩)




## ៣- ក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការនានា
### ក- សមាសភាពក្រុមប្រឹក្សាភិបាល

| ល.រ | ឈ្មោះអភិបាល | តំណែង | កាលបរិច្ឆេទ ក្លាយជាអភិបាល | កាលបរិច្ឆេទបញ្ចប់ អាណត្តិបច្ចុប្បន្ន | គុណវុឌ្ឍិ |
|---|---|---|---|---|---|
| ១ | លោក Sudargo Harsono | ប្រធាន | ១២ កញ្ញា ២០១៦ | ១១ កញ្ញា ២០១៩ | បរិញ្ញាបត្រជាន់ខ្ពស់ ហិរញ្ញវត្ថុ និងទីផ្សារ |
| ២ | កញ្ញា Duangdao Wongpanitkrit | សមាជិក | ១២ កញ្ញា ២០១៦ | ១១ កញ្ញា ២០១៩ | បរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងពាណិជ្ជកម្ម |
| ៣ | លោក Rohit Khanna | សមាជិក | ១២ កញ្ញា ២០១៦ | ១១ កញ្ញា ២០១៩ | បរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងពាណិជ្ជកម្ម |
| ៤ | លោក Chandrashekar Subramanian Krishoolndmangalam | សមាជិក | ១២ កញ្ញា ២០១៦ | ១១ កញ្ញា ២០១៩ | បរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងពាណិជ្ជកម្ម |
| 5 | លោក Piyasak Ukritnukun | សមាជិក | ១២ កញ្ញា ២០១៦ | ០១ មេសា ២០១៩ | បរិញ្ញាបត្រ គ្រប់គ្រងពាណិជ្ជកម្ម និងហិរញ្ញវត្ថុ |
| ៦ | លោក ឡុញ ហៃ | សមាជិក | ២៨ មិថុនា ២០១៧ | ២៧ មិថុនា ២០២០ | បរិញ្ញាបត្រ |

| | | | | | |
|---|---|---|---|---|---|
| ៧ | លោក ឌី ដាវុឌ្ឍ | សមាជិក | ២៨ មិថុនា ២០១៧ | ២៧ មិថុនា ២០២០ | បណ្ឌិត |
| ៨ | លោកស្រី តាល់ ណៃរីម | សមាជិក | ២៨ មិថុនា ២០១៧ | ០១ មេសា ២០១៩ | បរិញ្ញាបត្រ |
| ៩ | លោក ហួត អៀងតុង | សមាជិក | ១២ កញ្ញា ២០១៦ | ១១ កញ្ញា ២០១៩ | បរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងពាណិជ្ជកម្ម |

**ឈ្មោះលេខាធិការក្រុមហ៊ុន លោក ជីន បូរាណច័ន្ទបូរ៉ាត់**

**ខ- អភិបាលជាភាគហ៊ុននិក ជាកម្មសិទ្ធិករ ឬជាសហកម្មសិទ្ធិកររបស់ក្រុមហ៊ុន ឬ សហគ្រាសផ្សេងទៀត**

| ល.រ | ឈ្មោះរបស់អភិបាល | ឈ្មោះក្រុមហ៊ុនពាក់ព័ន្ធ | អភិបាល ឬភាគហ៊ុនិក ឬ កម្មសិទ្ធិករ ឬសហកម្មសិទ្ធិករ |
|---|---|---|---|
| ១ | គ្មាន | គ្មាន | គ្មាន |

**គ-តួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាល**

- អនុម័តផែនការថវិកាប្រចាំឆ្នាំរបស់ ហត្ថាកសិករ
- អនុម័តយុទ្ធសាស្រ្តអភិវឌ្ឍក្រុមហ៊ុន
- អនុម័តលើប្រាក់កម្ចីដែល ហត្ថាកសិករ ខ្ចីពីស្ថាប័នខាងក្រៅ
- លើកសំណើជូនភាគហ៊ុនិកដើម្បីបង្កើន ឬបន្ថយដើមទុន
- លើកសំណើជូនភាគហ៊ុនិកដើម្បីជ្រើសរើស និងតែងតាំងសវនករគណនេយ្យឯករាជ្យ
- អនុម័តគោលការណ៍លាភការរបស់ថ្នាក់គ្រប់គ្រង និងកម្មករនិយោជិត

**ឃ-សេចក្តីសម្រេច និងលទ្ធផលការងាររបស់ក្រុមប្រឹក្សាភិបាល**

នៅត្រីមាសទី១ ឆ្នាំ២០១៩ ក្រុមប្រឹក្សាភិបាលបានប្រារព្ធកិច្ចប្រជុំរបស់ខ្លួនចំនួន៣លើកដោយបានអនុម័តកិច្ចការសំខាន់ៗដូច ខាងក្រោម៖

- អនុម័តគោលការណ៍អភិបាលកិច្ចអាជីវកម្ម
- លើកអនុសាសន៍ជូនភាគហ៊ុនិកដើម្បីបង្កើនដើមទុនចុះបញ្ជីបន្ថែមចំនួន ៤០ លានដុល្លារអាមេរិក
- អនុម័តលទ្ធផលវាយតម្លៃហានិភ័យសាច់ប្រាក់ងាយស្រួល និងហានិភ័យទីផ្សារ
- អនុម័តការធ្វើបច្ចុប្បន្នភាពលើគោលនយោបាយគ្រប់គ្រងហានិភ័យប្រតិបត្តិការ
- អនុម័តការធ្វើបច្ចុប្បន្នភាពលើគោលនយោបាយគ្រប់គ្រងហានិភ័យឥណទាន
- អនុម័តការធ្វើបច្ចុប្បន្នភាពលើគោលនយោបាយជ្រើសរើសធនធានមនុស្ស
- អនុម័តរបាយការណ៍ត្រួតពិនិត្យផ្ទៃក្នុងប្រចាំឆ្នាំ

**ង-ការបណ្តុះបណ្តាលអភិបាល**

អភិបាលទទួលបានការបណ្តុះបណ្តាល ដើម្បីធ្វើបច្ចុប្បន្នភាពចំណេះជំនាញក្នុងការដឹកនាំ និងគ្រប់គ្រងក្រុមហ៊ុន។

### ច-គណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាភិបាល

#### ច-១-គណៈកម្មាធិការសវនកម្ម

##### ច-១-១-សមាសភាព

| ល.រ | ឈ្មោះ | តំណែង | |
|---|---|---|---|
| | | ក្នុងក្រុមហ៊ុន | ក្នុងគណៈកម្មាធិការ |
| ១ | លោក ឌី ដាវុឌ្ឍ | គ្មាន | ប្រធាន |
| ២ | កញ្ញា Duangdao Wongpanitkrit | គ្មាន | សមាជិក |
| ៣ | លោក ឡូញ ហៃ | គ្មាន | សមាជិក |

##### ច-១-២-សកម្មភាពការងារ

នៅក្នុងត្រីមាសទី១ ឆ្នាំ ២០១៩ គណៈកម្មាធិការសវនកម្មបានប្រារព្ធ កិច្ចប្រជុំរបស់ខ្លួនចំនួន បីដងដើម្បីពិភាក្សា របាយការណ៍សវនកម្មផ្ទៃក្នុងប្រចាំខែ និងរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្ម ដោយស្នងការគណនេយ្យឯករាជ្យសម្រាប់ ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០១៨។

**ច-១-៣-បញ្ហាប្រឈម** ៖នៅក្នុងត្រីមាសទី១ ឆ្នាំ ២០១៩ គណៈកម្មាធិការសវនកម្មពុំមានបញ្ហាប្រឈមទេ។

#### ច-២-គណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម ទ្រព្យអកម្ម និងហានិភ័យ

##### ច-២-១-សមាសភាព

| ល.រ | ឈ្មោះ | តំណែង | |
|---|---|---|---|
| | | ក្នុងក្រុមហ៊ុន | ក្នុងគណៈកម្មាធិការ |
| ១ | លោកស្រី តាល់ ណៃអ៊ីម | គ្មាន | ប្រធាន |
| ២ | កញ្ញា Duangdao Wongpanitkrit | គ្មាន | សមាជិក |
| ៣ | លោក Chandrashekar Subramanian Krishoolndmangalam | គ្មាន | សមាជិក |
| ៤ | លោក Rohit Khanna | គ្មាន | សមាជិក |

##### ច-២-២-សកម្មភាពការងារ

នៅក្នុងត្រីមាសទី១ ឆ្នាំ ២០១៩ គណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម ទ្រព្យអកម្មបានប្រារព្ធ កិច្ចប្រជុំរបស់ខ្លួនចំនួនបីដង ដើម្បីពិនិត្យលើរបាយរណ៍ហិរញ្ញវត្ថុរបស់ថ្នាក់គ្រង និងរបាយការណ៍គ្រប់គ្រងហានិភ័យ។

### ច-២-៣-បញ្ហាប្រឈម

នៅក្នុងត្រីមាសទី១ ឆ្នាំ ២០១៩ គណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម ទ្រព្យអកម្ម និងហានិភ័យពុំមានបញ្ហាប្រឈមទេ។

### ច-៣-គណៈកម្មាធិការតែងតាំង និងផ្តល់តម្លៃការ

### ច-៣-១-សមាសភាព

| ល.រ | ឈ្មោះ | តំណែង | |
|---|---|---|---|
| | | ក្នុងក្រុមហ៊ុន | ក្នុងគណៈកម្មាធិការ |
| ១ | លោក ឡូញ ហៃ | គ្មាន | ប្រធាន |
| ២ | លោក Sudargo Harsono | គ្មាន | សមាជិក |
| ៣ | លោក ហួត អៀងតុង | ប្រធានអគ្គនាយក | សមាជិក |

### ច-៣-២-សកម្មភាពការងារ

នៅក្នុងត្រីមាសទី១ ឆ្នាំ ២០១៩ គណៈកម្មាធិការតែងតាំង និងផ្តល់តម្លៃការបានប្រារព្ធកិច្ច ប្រជុំរបស់ខ្លួនចំនួនបីលើកដើម្បី ពិនិត្យរបាយការណ៍គ្រប់គ្រងធនធានមនុស្ស និងផ្តល់អនុសាសន៍ដល់ក្រុមប្រឹក្សាភិបាលដើម្បីអនុម័តគោលនយោបាយ ជ្រើសរើសបុគ្គលិក។

### ច-៣-៣-បញ្ហាប្រឈម

នៅក្នុងត្រីមាសទី១ ឆ្នាំ ២០១៩ គណៈកម្មាធិការតែងតាំង និងផ្តល់តម្លៃការពុំមានបញ្ហាប្រឈមទេ។

### ច-៤-គណៈកម្មាធិការបច្ចេកវិទ្យាព័ត៌មាន

### ច-៤-១-សមាសភាព

| ល.រ | ឈ្មោះ | តំណែង | |
|---|---|---|---|
| | | ក្នុងក្រុមហ៊ុន | ក្នុងគណៈកម្មាធិការ |
| ១ | លោក Rohit Khanna | គ្មាន | ប្រធាន |
| ២ | លោក Piyasak Ukritnukun | គ្មាន | សមាជិក |
| ៣ | លោក ឌី ដាវុឌ្ឍ | គ្មាន | សមាជិក |

**ច-៤-២-សកម្មភាពការងារ**

នៅក្នុងត្រីមាសទី១ ឆ្នាំ ២០១៩ គណៈកម្មាធិការបច្ចេកវិទ្យាព័ត៌មានបានប្រារព្ធកិច្ចប្រជុំរបស់ ខ្លួនចំនួនមួយដងដើម្បីពិនិត្យ និងពិភាក្សាការវិនិយោគលើប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន សម្រាប់គាំទ្រប្រតិបត្តិការអាជីវកម្ម និងពិនិត្យលើគម្រោងផ្សេងៗ ដែលទាក់ទងនឹងព័ត៌មានវិទ្យា។

**ច-៤-៣-បញ្ហាប្រឈម**

នៅក្នុងត្រីមាសទី១ ឆ្នាំ ២០១៩ គណៈកម្មាធិការបច្ចេកវិទ្យាព័ត៌មានពុំមានបញ្ហាប្រឈមទេ។

**ច-៥-គណៈកម្មាធិការតែងតាំងនិងទានក្រុមប្រឹក្សាភិបាល**

**ច-៥-១-សមាសភាព**

| ល.រ | ឈ្មោះ | តំណែង | |
|---|---|---|---|
| | | ក្នុងក្រុមហ៊ុន | ក្នុងគណៈកម្មាធិការ |
| ១ | លោក Chandrashekar Subramanian Krishoolndmangalam | គ្មាន | ប្រធាន |
| ២ | លោក Piyasak Ukritnukun | គ្មាន | សមាជិក |
| ៣ | លោក ឡុញ ហៃ | គ្មាន | សមាជិក |
| ៤ | លោក ហួត អៀងតុង | គ្មាន | សមាជិក |

**ច-៥-២-សកម្មភាពការងារ**

នៅក្នុងត្រីមាសទី១ ឆ្នាំ ២០១៩ គណៈកម្មាធិការតែងតាំងនិងទានក្រុមប្រឹក្សាភិបាលពុំបានប្រារព្ធកិច្ចប្រជុំទេ។

**ច-៥-៣-បញ្ហាប្រឈម**

នៅក្នុងត្រីមាសទី១ ឆ្នាំ ២០១៩ គណៈកម្មាធិការតែងតាំងនិងទានក្រុមប្រឹក្សាភិបាលពុំមានបញ្ហាប្រឈមទេ។

## ៤- បុគ្គលិកជាន់ខ្ពស់

### ក-សមាសភាពបុគ្គលិកជាន់ខ្ពស់

| ល.រ | ឈ្មោះ | តំណែង | គុណវុឌ្ឍិ |
|---|---|---|---|
| ១ | លោក ហួត អៀងតុង | ប្រធានអគ្គនាយក | បរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងពាណិជ្ជកម្ម |
| ២ | លោក Wanchairabin Jitwattanatam | អនុប្រធានអគ្គនាយក | បរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងពាណិជ្ជកម្ម |
| ៣ | កញ្ញា អ៊ឹម វណ្ណិត | អគ្គនាយិកាប្រតិបត្តិការ និងអភិបាលកិច្ច | បរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងពាណិជ្ជកម្ម |
| ៤ | លោក មិច សុខមេត្រី | អគ្គនាយកអភិវឌ្ឍអាជីវកម្ម | បរិញ្ញាបត្រទីផ្សារ |
| ៥ | លោក ទូច លីណា | អគ្គនាយកអនុមតិឥណទាន | បរិញ្ញាបត្រគ្រប់គ្រងពាណិជ្ជកម្ម |
| ៦ | លោក ហ៊ឹម វិបុល | អគ្គនាយកហិរញ្ញវត្ថុ | បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកហិរញ្ញវត្ថុនិងគណនេយ្យ |
| ៧ | លោក រស់ វ៉ុល | អគ្គនាយកសវនកម្មផ្ទៃក្នុង | បរិញ្ញាបត្រជាន់ខ្ពស់ហិរញ្ញវត្ថុ និងគណនេយ្យ |
| ៨ | លោក ជីន បូរាណច័ន្ទបូរ៉ាត់ | អគ្គនាយកនីតិកម្ម | បរិញ្ញាបត្រជាន់ខ្ពស់នីតិឯកជន |
| ៩ | លោកស្រី ឆេង សុគន្ធ | អគ្គនាយិកាគ្រប់គ្រងហានិភ័យ | បរិញ្ញាបត្រជាន់ខ្ពស់ហិរញ្ញវត្ថុ និងធនាគារ |
| ១០ | លោក ដួង ច័ន្ទសុវិជ្ជា | អគ្គនាយកលក់ និងចែកចាយ | បរិញ្ញាបត្រជាន់ខ្ពស់ហិរញ្ញវត្ថុ និងធនាគារ |
| ១១ | លោក យឹម ទិត្យា | អគ្គនាយកព័ត៌មានវិទ្យា | បរិញ្ញាបត្រព័ត៌មានវិទ្យា |
| ១២ | លោក សេម សោភ័ណ | អគ្គនាយកធនធានមនុស្ស | បរិញ្ញាបត្រនីតិសាស្រ្តសាធារណៈ |
| ១៣ | កញ្ញា ហេង ស្រីប៉ុច | នាយិកាប្រតិបត្តិតាម | បរិញ្ញាបត្រហិរញ្ញវត្ថុ និងធនាគារ |

## ខ- តួនាទីភារកិច្ច និងការទទួលខុសត្រូវរបស់បុគ្គលិកជាន់ខ្ពស់

**លោក ហួត អៀងតុង**

ប្រធានអគ្គនាយក

- រៀបចំ និងដឹកនាំផែនការយុទ្ធសាស្ត្ររបស់ក្រុមហ៊ុន
- រៀបចំផែនការអាជីវកម្មរបស់ក្រុមហ៊ុន និងដាក់ជូនក្រុមប្រឹក្សាភិបាលអនុម័ត
- ទទួលបន្ទុកអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ធ្វើយ៉ាងណាឲ្យសម្រេចនូវផែនការដែលបានកំណត់
- គ្រប់គ្រងសកម្មភាពប្រតិបត្តិការអាជីវកម្មប្រចាំថ្ងៃរបស់ក្រុមហ៊ុន
- វាយតម្លៃលទ្ធផលប្រតិបត្តិការអាជីវកម្មរបស់ក្រុមហ៊ុន
- គ្រប់គ្រងគម្រោងផែនការអាជីវកម្មរបស់ក្រុមហ៊ុន
- វាយការណ៍នូវលទ្ធផលអាជីវកម្មជូនក្រុមប្រឹក្សាភិបាល

**លោក Wanchairabin Jitwattanatam**

អនុប្រធានអគ្គនាយក

- ចូលរួមក្នុងការរៀបចំផែនការយុទ្ធសាស្ត្ររបស់ក្រុមហ៊ុន
- ចូលរួមរៀបចំផែនការអាជីវកម្មរបស់ក្រុមហ៊ុន និងដាក់ជូន ក្រុមប្រឹក្សាភិបាលអនុម័ត
- ចូលរួមអនុវត្តនូវផែនការអាជីវកម្មដែលកំណត់ក្រុមប្រឹក្សាភិបាល
- ចូលរួមគ្រប់គ្រងប្រតិបត្តិការអាជីវកម្មរបស់ក្រុមហ៊ុន
- ចូលរួមវាយតម្លៃលទ្ធផលប្រតិបត្តិការអាជីវកម្មរបស់ក្រុមហ៊ុន
- គ្រប់គ្រង និងសម្របសម្រួលនូវរាល់គម្រោងផែនការអាជីវកម្មក្រុមហ៊ុន

**កញ្ញា អ៊ឹម វណ្ណិត**

អគ្គនាយិកាប្រតិបត្តិការ និងអភិបាលកិច្ច

- ចូលរួមក្នុងការរៀបចំផែនការយុទ្ធសាស្ត្ររបស់ក្រុមហ៊ុន
- គ្រប់គ្រងការងារអភិបាលកិច្ចក្រុមហ៊ុន
- គ្រប់គ្រងប្រតិបត្តិការសាខា
- គ្រប់គ្រង និងគាំទ្រសាខា

**លោក ម៉ិច សុខមេត្រី**

អគ្គនាយកអភិវឌ្ឍន៍អាជីវកម្ម

- ចូលរួមក្នុងការរៀបចំផែនការយុទ្ធសាស្ត្ររបស់ក្រុមហ៊ុន
- រៀបចំ និងអភិវឌ្ឍន៍ផែនការអាជីវកម្មរបស់ក្រុមហ៊ុន
- អនុវត្តនូវផែនការអាជីវកម្មដែលកំណត់ក្រុមប្រឹក្សាភិបាល
- វាយតម្លៃលទ្ធផលប្រតិបត្តិការអាជីវកម្មរបស់ក្រុមហ៊ុន
- ដឹកនាំ បង្កើត និងអភិវឌ្ឍន៍ផលិតផលរបស់ក្រុមហ៊ុន

**លោក ទូច លីណា**

អគ្គនាយកអនុម័តឥណទាន

- រៀបចំ និងដឹកនាំផែនការយុទ្ធសាស្ត្រប្រមូលឥណទាន និងគុណភាពផលបត្រឥណទាន
- គ្រប់គ្រង និងធានានូវគុណភាពផលបត្រឥណទាន
- គ្រប់គ្រងការប្រមូលឥណទានប្រកបដោយប្រសិទ្ធភាព
- បង្កើត និងអភិវឌ្ឍន៍នូវគោលនយោបាយប្រមូលឥណទាន និងអនុម័តឥណទាន

**លោក ហ៊ឹម វិបុល**

អគ្គនាយកហិរញ្ញវត្ថុ

- ដឹកនាំ ចាត់ចែង និងគ្រប់គ្រងនាយកដ្ឋានហិរញ្ញវត្ថុ នាយកដ្ឋាន រតនាភិបាល និងនាយកដ្ឋានផែនការហិរញ្ញវត្ថុ
- គ្រប់គ្រង និងធានាថារបាយការណ៍ហិរញ្ញវត្ថុអនុលោមតាមបទដ្ឋានច្បាប់
- គ្រប់គ្រង និងត្រួតពិនិត្យផែនការហិរញ្ញវត្ថុប្រចាំឆ្នាំ និងគ្រប់គ្រងចំនាយ
- គ្រប់គ្រង និងរៀបចំរបាយការណ៍ហិរញ្ញវត្ថុ
- គ្រប់គ្រងមូលនិធិ និងប្រភពទុនខាងក្រៅ

**លោក រស់ រ៉ុល**

អគ្គនាយកសវនកម្មផ្ទៃក្នុង

- រៀបចំ និងដឹកនាំផែនការយុទ្ធសាស្ត្រសនវកម្មផ្ទៃក្នុង
- វាយតម្លៃហានិភ័យ និងត្រួតពិនិត្យប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង
- អនុវត្តនូវផែនការសវនកម្មផ្ទៃក្នុង ដែលកំណត់ក្រុមប្រឹក្សាភិបាល
- បង្កើត និងអភិវឌ្ឍន៍គោលនយោបាយសវនកម្ម
- វាយការណ៍នូវលទ្ធផលសវនកម្មផ្ទៃក្នុងទៅក្រុមប្រឹក្សាភិបាល

**លោក ជឺន បូរាណច័ន្ទបូរ៉ាត់**

អគ្គនាយកនីតិកម្ម

- ធានានូវប្រតិបត្តិការរបស់ក្រុមហ៊ុនអនុលោមទៅតាមច្បាប់ និងបទប្បញ្ញាតិដែលពាក់ព័ន្ធ
- គ្រប់គ្រង និងដោះស្រាយវិវាទរបស់ក្រុមហ៊ុនទាំងផ្នែកខាងក្នុង និង ខាងក្រៅ
- ផ្តល់នូវការប្រឹក្សាទិដ្ឋភាពផ្នែកច្បាប់ដល់ក្រុមប្រឹក្សាភិបាល គណៈ គ្រប់គ្រង និងបុគ្គលិក

**លោកស្រី ឆេង សុគន្ធ**

អគ្គនាយិកាគ្រប់គ្រងហានិភ័យ

- រៀបចំផែនការយុទ្ធសាស្ត្រក្នុងគ្រប់គ្រងហានិភ័យនានារបស់ក្រុមហ៊ុន
- កំណត់ វាយតម្លៃ ត្រួតពិនិត្យ និងគ្រប់គ្រងហានិភ័យនានា ឲ្យនៅ កម្រិតទាបបំផុត
- បង្កើត និងអភិវឌ្ឍន៍គោលនយោបាយគ្រប់គ្រងហានិភ័យ
- រៀបចំរបាយការណ៍គ្រប់គ្រងហានិភ័យជូនក្រុមប្រឹក្សាភិបាល

**លោក ដួង ច័ន្ទសុវិជ្ជា**

អគ្គនាយកលក់ និងចែកចាយស្តីទី

- គ្រប់គ្រង និងធានាថាផលបត្រឥណទានសម្រេចទៅតាម ផែនការ កំណត់
- គ្រងគ្រង និងធានាថាផលបត្រប្រាក់សន្សំ និងផលិតផលហិរញ្ញវត្ថុ ផ្សេងៗ សម្រេចទៅតាមផែនការកំណត់
- គ្រប់គ្រងប្រសិទ្ធភាព និងសមិទ្ធិផលសាខា

**លោក យឹម ទិត្យា**

អគ្គនាយកព័ត៌មានវិទ្យា

- រៀបចំ និងដឹកនាំផែនការយុទ្ធសាស្ត្រប្រព័ន្ធព័ត៌មានវិទ្យា
- គ្រប់គ្រងអភិបាលកិច្ចប្រព័ន្ធព័ត៌មានវិទ្យា
- គ្រប់គ្រង និងវាយតម្លៃហានិភ័យប្រព័ន្ធព័ត៌មានវិទ្យា
- បង្កើត និងអភិវឌ្ឍន៍គោលនយោបាយគ្រប់គ្រងព័ត៌មានវិទ្យា

**លោក សេម សោភ័ណ**

អគ្គនាយកធនធានមនុស្ស

- រៀបចំ និងដឹកនាំផែនការយុទ្ធសាស្ត្រធនធានមនុស្ស
- ធានាបាននូវការប្រតិបត្តិការធនធានមនុស្ស អនុលោមតាមច្បាប់ និង បទប្បញ្ញាតិផ្សេង
- រៀបចំផែនការធនធានមនុស្សប្រចាំឆ្នាំ
- ដឹកនាំ និងរៀបចំផែនការបណ្តុះបណ្តាល និងអភិវឌ្ឍន៍ធនធានមនុស្ស
- ដឹកនាំ និងរៀបចំចែងចាត់អភិវឌ្ឍនអង្គភាព
- រៀបចំផែនការប្រាក់សំណង និងអត្ថប្រយោជន៍
- បង្កើត និងអភិវឌ្ឍន៍គោលនយោបាយគ្រប់គ្រងធនធានមនុស្ស

**កញ្ញា ហេង ស្រីប៉ុច**

នាយិកានាយកដ្ឋានប្រតិបត្តិតាម

- រៀបចំ និងដឹកនាំផែនការយុទ្ធសាស្ត្រប្រតិបត្តិតាមនៅក្នុងក្រុមហ៊ុន
- ធានាថាប្រតិបត្តិការអាជីវកម្មប្រតិបត្តិតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិ
- ធានាថាអាជីវកម្មរបស់ក្រុមហ៊ុនប្រតិបត្តិតាម AML/CFT
- ធានាថាប្រតិបត្តិការអាជីវកកម្មអនុលោមតាមក្រុមហ៊ុនមេ (Parent Company)
- បង្កើត និងអភិវឌ្ឍន៍គោលនយោបាយប្រតិបត្តិតាម

### ឃ-ការបណ្តុះបណ្តាលបន្តសម្រាប់បុគ្គលិកជាន់ខ្ពស់

នៅក្នុងត្រីមាសទី១ ឆ្នាំ ២០១៩ ហត្ថាកសិករ ពុំមានការបណ្តុះបណ្តាលបន្តសម្រាប់បុគ្គលិកជាន់ខ្ពស់នោះទេ។

## ៥- ការជាប់ពាក់ព័ន្ធ របស់អភិបាល និងបុគ្គលិកជាន់ខ្ពស់ក្នុងដំណើរផ្លូវច្បាប់

នៅក្នុងត្រីមាសទី១ ឆ្នាំ ២០១៩ ពុំមានអភិបាល ឬ បុគ្គលិកជាន់ខ្ពស់ណាម្នាក់រងការចោទប្រកាន់ ឬ ប្តឹងផ្តល់ឡើយ។

## ៦- លាភការ ឬប្រាក់បំណាច់របស់អភិបាល និងបុគ្គលិកជាន់ខ្ពស់

| ល.រ | ឈ្មោះ | មុខតំណែង | ចំណាត់ថ្នាក់លាភការ |
|---|---|---|---|
| ១ | លោក ហួត អៀងតុង | ប្រធានអគ្គនាយក | ក |
| ២ | លោក Wanchairabin Jitwattanatam | អនុប្រធានអគ្គនាយក | ក |
| ៣ | កញ្ញា អ៊ឹម វណ្ណិត | អគ្គនាយិកាប្រតិបត្តិការ និងអភិបាលកិច្ច | ក |
| ៤ | លោក ម៉ិច សុខមេត្រី | អគ្គនាយកអភិវឌ្ឍអាជីវកម្ម | ខ |
| ៥ | លោក ទូច លីណា | អគ្គនាយកអនុមតិឥណទាន | ខ |
| ៦ | លោក ហ៊ឹម វិបុល | អគ្គនាយកហិរញ្ញវត្ថុ | ខ |
| ៧ | លោក រស់ វ៉ុល | អគ្គនាយកសវនកម្មផ្ទៃក្នុង | ខ |
| ៨ | លោក ជីន បូរាណច័ន្ទបូរ៉ាត់ | អគ្គនាយកនីតិកម្ម | ខ |
| ៩ | លោកស្រី ឆេង សុគន្ធ | អគ្គនាយិកាគ្រប់គ្រងហានិភ័យ | ខ |
| ១០ | លោក ដួង ច័ន្ទសុវិជ្ជា | អគ្គនាយកលក់ និងចែកចាយ | ខ |
| ១១ | លោក យឹម ទិត្យា | អគ្គនាយកព័ត៌មានវិទ្យា | ខ |
| ១២ | លោក សេម សោភ័ណ | អគ្គនាយកធនធានមនុស្ស | ខ |
| ១៣ | កញ្ញា ហេង ស្រីប៉ុច | នាយិកាប្រតិបត្តិតាម | គ |

ក- ឈ្មោះតំណែងអភិបាល និងបុគ្គលិកជាន់ខ្ពស់ និងប្រាក់បំណាច់ ឬលាភការដែលទទួលបាន

| តារាងចំណាត់ថ្នាក់លាភការ | អប្បបរមា | អតិបរមា |
|---|---|---|
| ក | ៧,៦០០ ដុល្លារអាមេរិក | ២៧,០០០ ដុល្លារអាមេរិក |
| ខ | ៦,៨០០ ដុល្លារអាមេរិក | ១១,០០០ ដុល្លារអាមេរិក |
| គ | ៤,៦០០ ដុល្លារអាមេរិក | ៦,០០០ ដុល្លារអាមេរិក |

ខ- ចំនួនប្រាក់បំណាច់ ឬលាភការសរុបដែលបើកឱ្យអភិបាលមិនប្រតិបត្តិ

ហត្ថាកសិករ មានអភិបាលមិនប្រតិបត្តិចំនួន ៨ រូប ដែលជាសមាជិកក្រុមប្រឹក្សាភិបាល តំណាងឲ្យក្រុមហ៊ុន ដែល មិនមានប្រតិបត្តិការការងារជាមួយហត្ថាកសិករគឺទទួលបានប្រាក់បំណាច់ ឬលាភការ សរុបចំនួន ១៦,០០០ ដុល្លារអាមេរិកគត់។

គ- ចំនួនប្រាក់បំណាច់ ឬលាភការជាកញ្ចប់ដែលបានបើកឱ្យអភិបាល និងបុគ្គលិកជាន់ខ្ពស់

ហត្ថាកសិករ មានអភិបាលសរុបចំនួន ៨ រូប និងបុគ្គលិកជាន់ខ្ពស់ចំនួន ១៣ រូប ។ ខាងក្រោម គឺជាចំនួនសរុប (ប្រាក់បៀវត្សនិងប្រាក់បំណាច់មិនបូកបញ្ចូលប្រាក់សោធននិវត្តន៍)៖ អភិបាលទាំងអស់ ១៦,០០០ ដុល្លារអាមេរិកគត់ និងបុគ្គលិកជាន់ខ្ពស់ទាំងអស់ ៧៤៤,៦៣៧ ដុល្លារអាមេរិកគត់។

ឃ- ចំនួនប្រាក់បំណាច់ ឬលាភការសរុបសម្រាប់រយៈពេល ០១ (មួយ) ឆ្នាំខាងមុខដែលត្រូវផ្តល់ជូនអភិបាល ឬបុគ្គលិកជាន់ខ្ពស់

ប្រាក់បំណាច់ ឬលាភការសរុបសម្រាប់រយៈពេល ០១ ឆ្នាំខាងមុខ ដែលត្រូវផ្តល់ជូនអភិបាល និង បុគ្គលិកជាន់ខ្ពស់មានដូចខាងក្រោម៖ អភិបាលទាំងអស់ ៧២,០០០ ដុល្លារអាមេរិកគត់និងបុគ្គលិកជាន់ខ្ពស់ទាំងអស់ ១,៩១១,៤០១ ដុល្លារអាមេរិកគត់។

ង- ការបង្កើនប្រាក់បំណាច់ ឬលាភការសរុបក្នុងចំនួនច្រើនដល់អភិបាល ឬបុគ្គលិកជាន់ខ្ពស់របស់ក្រុមហ៊ុននៅក្នុងឆ្នាំ សារពើពន្ធ ឬអនាគត

ក្រុមប្រឹក្សាភិបាលបានអនុម័ត និងឯកភាពជាគោលការណ៍ក្នុងការដំឡើងប្រាក់បៀវត្សចំនួន ៨% ជូនបុគ្គលិកជាន់ខ្ពស់ និងនិយោជិតរបស់ហត្ថាកសិករ នាថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ ២០១៨ ។

៧- ក្រមសីលធម៌សម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់

គោលបំណងនៃក្រមប្រតិបត្តិសីលធម៌ និងគោលការណ៍នៅគ្រប់ពេលធ្វើសកម្មភាពអាជីវកម្មរបស់ហត្ថាកសិករ យើងអនុវត្តតាមក្រមប្រតិបត្តិសីលធម៌ និងគោលការណ៍ដែលជួយធានាក្នុងការបន្តកិច្ចការរបស់យើងប្រកបដោយសុចរិតភាព។ គ្រប់បុគ្គលិកគ្រប់ជាន់ថ្នាក់ទាំងអស់ត្រូវប្រកាន់ខ្ជាប់នូវការទទួលខុសត្រូវ ខ្ពស់តាមស្តង់ដាក្រមសីលធម៌ក្នុងការប្រកបអាជីវកម្ម។

**ក. ការប្តេជ្ញាចិត្តរបស់បុគ្គលិក**

គ្រប់បុគ្គលិកទាំងអស់មានការប្តេជ្ញាចិត្តដើម្បីទទួលបានជោគជ័យទៅលើលទ្ធផលការងារ ទោះបីជាយើងត្រូវចំណាយពេលវេលា និងកំលាំងកាយចិត្ត។ លើសពីនេះទៅទៀតបុគ្គលិកហត្ថាកសិករត្រូវសម្របខ្លួនទៅនឹង ក្រមសីលធម៌ រួមមាន៖

- គោរពតាមច្បាប់ និង បទប្បញ្ញត្តិ គ្រប់គ្រងអាជីវកម្ម
- ត្រូវមានភាពស្មោះត្រង់ ស្មើភាព និង ទុកចិត្តបាន ក្នុងរាល់សកម្មភាព និងទំនាក់ទំនងល្អ
- ជៀសវាងរាល់ទំនាស់ផលប្រយោជន៍រវាងការងារ និង កិច្ចការផ្ទាល់ខ្លួន
- ជំរុញនូវបរិយាកាសស្មើភាពក្នុងការងាររហូតដល់គ្រប់សមាជិកនៃសហគមន៍ហត្ថាកសិករដទៃទៀត
- ខិតខំបង្កើតសុវត្ថិភាពនៅកន្លែងធ្វើការ និង ចូលរួមក្នុងការការពារបរិស្ថាន
- តាមរយៈភាពជាអ្នកដឹកនាំនៅគ្រប់ជាន់ថ្នាក់ ត្រូវរក្សាវប្បធម៌ទទួលស្គាល់ការអនុវត្តក្រមសីលធម៌ឱ្យតម្លៃ និងជាគំរូដល់បុគ្គលិកគ្រប់រូប។
- បុគ្គលិកត្រូវប្រកាន់ខ្ជាប់គ្រប់គ្នានូវក្រមសីលធម៌ ក្នុងពេលបម្រើការងារនៅហត្ថាកសិករ។ អ្នកគ្រប់គ្រងមានភារកិច្ចអង្កេត និង ធានានូវការអនុវត្តក្រមសីលធម៌របស់បុគ្គលិក។ អ្នកបំពានក្រមនេះត្រូវទទួលរងទណ្ឌកម្មដែល អាចរហូតដល់បញ្ឈប់ពីការងារ។

**ខ.គោលការណ៍ចម្បងក្នុងក្រមសីលធម៌ ៖**

**១. ឧត្តមភាពនៃបទប្បញ្ញត្តិ**

ហត្ថាកសិករប្រឈមនឹងការកើនឡើងជាលំដាប់នៃបទប្បញ្ញត្តិ និងសកម្មភាពនៃការអនុវត្តច្បាប់ជាច្រើន។ ក្នុងបរិយាកាសនេះ ទាមទារឱ្យរាល់និយោជិត និងអ្នកគ្រប់គ្រងយល់ និងមានចំណេះដឹង ហើយត្រូវប្តេជ្ញាចិត្ត ដើម្បីឧត្តមភាព នៃបទប្បញ្ញត្តិ។

**២. ការធ្វើការជាមួយអតិថិជន និង អ្នកផ្គត់ផ្គង់**

**ក.ការទូទាត់មិនត្រឹមត្រូវ**

ហត្ថាកសិករ ហាមឃាត់ក្នុងការធ្វើប្រតិបត្តិការទូទាត់មិនត្រឹមត្រូវ នៅគ្រប់នាយកដ្ឋានឬសាខា (Business Areas) ទាំងអស់រួមទាំងក្នុងវិស័យរដ្ឋនិងវិស័យឯកជនផងដែរ។ ការទូទាត់ទាំងនោះគឺអាចទទួលយកបានស្របតាមហត្ថាកសិករ និងសេចក្តីណែនាំនៃអាជីវកម្ម (Business Guideline)។

**ខ. ការទំនាក់ទំនង ជាមួយអ្នកផ្គត់ផ្គង់**

ទំនាក់ទំនងហត្ថាកសិករ ជាមួយអ្នកផ្គត់ផ្គង់ត្រូវបានបង្កើតឡើងដោយស្របតាមច្បាប់ក្នុងការអនុវត្តឱ្យ មានប្រសិទ្ធភាព និងមានស្មើភាពគ្នា។ យើងរំពឹងថាអ្នកផ្គត់ផ្គង់ នឹងគោរពតាមលក្ខខណ្ឌច្បាប់ ដែលតម្រូវ ឱ្យផ្តល់ ជូននូវភាពស្មើគ្នា ផ្តល់នូវសុវត្ថិភាព និងសុខមាលភាពនៅកន្លែងធ្វើការងារ និងការពារគុណភាព បរិយាកាស ការងារដល់កម្មករ។

**គ. ការគ្រប់គ្រងទៅលើពាណិជ្ជកម្មអន្តរជាតិ**

ហត្ថាកសិករបានអនុវត្ត តាមគោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិ និង កម្មវិធីទណ្ឌកម្ម ដែលហៅថា ទណ្ឌកម្មអង្គការសហប្រជាជាតិ (UN Sanction)។ យើងក៏ធ្វើការផ្ទៀងផ្ទាត់រាល់ប្រតិបត្តិការ ជាមួយលក្ខខណ្ឌដែលបាន កំណត់ ទៅលើការហាមឃាត់ប្រតិបត្តិការជាមួយប្រទេស និងបុគ្គលដែលបានហាមឃាត់ក្នុងការធ្វើប្រតិបត្តិការជាមួយ។

**ឃ. ការទប់ស្កាត់ការសម្អាតប្រាក់**

ហត្ថាកសិករ បានប្តេជ្ញាចិត្តក្នុងអនុវត្តតាមយ៉ាងពេញលេញនូវច្បាប់ប្រឆាំងនឹងការសម្អាតប្រាក់ និងហិរញ្ញប្បទាន ភេរវកម្ម។ ហត្ថាកសិករ ធ្វើអាជីវកម្មតែជាមួយអតិថិជនដែលមានកេរ្តិ៍ឈ្មោះក្នុងសកម្មភាព អាជីវកម្មស្របច្បាប់ដែលមានប្រភពហិរញ្ញវត្ថុ បានមកពីប្រភពស្របច្បាប់តែប៉ុណ្ណោះ។ ហត្ថាកសិករ អនុវត្តការកំណត់មូលដ្ឋានហានិភ័យក្នុង "ការស្គាល់អតិថិជន" (KYC) ដើម្បីកំណត់សំណួរដែលទាក់ទងនឹងហានិភ័យអតិថិជន និង ជាបន្តបន្ទាប់ដើម្បីការពារ និងទប់ស្កាត់ទៅលើប្រតិបត្តិការ ដែលមានលក្ខណៈគួរឱ្យសង្ស័យនិង មិនអាចទទួលយកបាន។

**ង. ឯកជនភាព**

ហត្ថាកសិករ បានប្តេជ្ញាចិត្តក្នុងការប្រើប្រាស់ទិន្នន័យផ្ទាល់ខ្លួនរបស់អតិថិជនដោយមានការទទួល ខុសត្រូវ និងអនុវត្ត តាមច្បាប់ឯកជនភាពដែលមាន។ ការប្រមូល ដំណើរការ និងការប្រើប្រាស់ទិន្នន័យផ្ទាល់ខ្លួនសម្រាប់តែគោលបំណងអាជីវកម្ម ស្របច្បាប់តែប៉ុណ្ណោះ ។ ធ្វើការថែរក្សា ដើម្បីការពារពីការ ចូលយកឯកសារពីទិន្នន័យបុគ្គល ឬការបាត់បង់ដោយចៃដន្យ ឬការលប់នូវទិន្នន័យផ្ទាល់ខ្លួនរបស់អតិថិជនដោយគ្មានការអនុញ្ញាត។

**៣. អាជីវកម្មជាមួយរដ្ឋាភិបាល**

នៅពេលដែល ហត្ថាកសិករ ធ្វើការជាដៃគូរដោយផ្ទាល់ឬដោយប្រយោលជាមួយនឹងរដ្ឋាភិបាល និង សហគ្រាស ដែលគ្រប់គ្រងដោយរដ្ឋាភិបាល (នៅករណីដែលការងាររបស់យើង ជាញឹកញាប់គឺជាប់ទាក់ទងជាមួយនឹងភ្នាក់ងារ និងមន្ត្រី រដ្ឋាភិបាល) បុគ្គលិក ហត្ថាកសិករ ត្រូវតែអនុវត្តតាមស្តង់ដារីជ្ជាជីវៈខ្ពស់បំផុត និងគោរពតាមច្បាប់ និងបទប្បញ្ញត្តិ ដទៃទៀតរួម ទាំងការអនុវត្តតាមលក្ខខណ្ឌតម្រូវ ពិសេសមួយចំនួន ដែលបានផ្សារភ្ជាប់នឹងប្រតិបត្តិការរបស់រដ្ឋាភិបាល។

**៤. ការប្រកួតប្រជែងជាសកល**

តម្រូវឱ្យត្រួតពិនិត្យជាមុន ក្នុងគោលបំណងទប់ស្កាត់ការប្រកួតប្រជែងមិនស្មោះត្រង់រវាងដៃគូរប្រជែង។ មិនត្រូវឱ្យ ជួយសម្រួល ដល់អតិថិជនណាមួយ ដែលមានបំណងប្រើប្រាស់នូវសេវាកម្មរបស់យើងជា មធ្យោបាយ ក្នុងការគេចវេស ពីច្បាប់ប្រកួតប្រជែង ដើម្បីជួយសម្រួលដល់ការរួមបញ្ចូល ឬការទិញយក ឬដើម្បីជួយសម្រួលដល់ សកម្មភាពទីផ្សារដោយមិន ស្របច្បាប់ណាមួយ ដែលលទ្ធផលនឹងទទួលបាននូវការផ្តាច់មុខក្នុងទីផ្សារ ឬ ច្បាប់ប្រឆាំងនឹងការលក់បង្ខូចថ្លៃ។

**៥. សហគមន៍ ហត្ថាកសិករ**

ភាពស្មើគ្នាក្នុងការអនុវត្តការងារហត្ថាកសិករ ប្តេជ្ញាចិត្តដើម្បី អនុវត្តតាមរាល់ច្បាប់ដែលជាប់ទាក់ទងនឹងឯកជនភាព ម៉ោងធ្វើការ ប្រាក់ឈ្នួល គ្មានការរើសអើងបុគ្គលិក និង សេរីភាពក្នុងការចូលរួម។ ក៏ប៉ុន្តែក្នុងនាម

ហត្ថាកសិករ បុគ្គលិក មិនមានសិទ្ធិបញ្ចេញមតិគាំទ្រទៅគណបក្សនយោបាយណាមួយឡើយ ចូលរួមក្នុងយុទ្ធនាការបោះឆ្នោត ឬចូលរួមក្នុងជម្លោះនយោបាយឡើយ។ បន្ថែមលើការអនុវត្តតាមផ្លូវច្បាប់ យើងខិតខំក្នុងការបង្កើតបរិយាកាសដែលគិតគូ អំពីបុគ្គលិកទាំងអស់ នៅគ្រប់ទីកន្លែងដែល ហត្ថាកសិករធ្វើអាជីវកម្ម។

**៦. ការការពារទ្រព្យសកម្មរបស់ហត្ថាកសិករ**

ទំនាស់ផលប្រយោជន៍ក្នុងម៉ោងធ្វើការ ឬក្នុងពេលសម្រាករបស់យើង អ្វីដែលអ្នកធ្វើមិនត្រូវឱ្យមានទំនាស់ផលប្រយោជន៍ ជាមួយនឹងការទទួលខុសត្រូវរបស់អ្នកជាមួយហត្ថាកសិករនោះទេ ។ គ្មានសកម្មភាពនៅកន្លែងធ្វើការ ឬក៏នៅផ្ទះ ដែល ធ្វើឱ្យប៉ះពាល់ដល់កេរ្តិ៍ឈ្មោះរបស់ ហត្ថាកសិករ ទេ។ ការប្រើប្រាស់ធនធានរបស់ ហត្ថាកសិករមិនត្រឹមត្រូវ ឬមិនសម ស្របត្រូវបានហាមឃាត់ផងដែរ។

**៧.ការទិញលក់ភាគហ៊ុន និងការផ្តល់ព័ត៌មានសម្ងាត់នៃភាគហ៊ុន**

ហាមឃាត់ចំពោះការទិញលក់មូលបត្រក្រុមហ៊ុនផ្សេងៗទៀតរួមទាំង ការទិញលក់មូលបត្ររបស់ Krungsri ទាំងដោយផ្ទាល់ ឬតាមរយៈសមាជិកក្រុមគ្រួសារ ឬបុគ្គលផ្សេង ឬតាមរយៈក្រុមហ៊ុនផ្សេង ក្នុងពេលដែលបុគ្គលិករបស់ យើងបានដឹងអំពី ព័ត៌មានផ្ទៃក្នុងរបស់ក្រុមហ៊ុន។

បុគ្គលិករបស់ហត្ថាកសិករ មិនត្រូវធ្វើការផ្តល់យោបល់ ឬធ្វើការណែនាំទៅកាន់នរណាម្នាក់ផ្សេងទៀតឱ្យទិញលក់ មូលបត្ររបស់ក្រុមហ៊ុនណាមួយរួមទាំង ហត្ថាកសិករ ក្នុងពេលដែលអ្នកបានដឹងអំពីព័ត៌មានផ្ទៃក្នុងរបស់ក្រុមហ៊ុន (ដែលត្រូវបានស្គាល់ថា “ការចែករំលែក”) ការផ្តល់ព័ត៌មានសម្ងាត់នៃភាគហ៊ុន (“Stock Tipping”)។

**៨- សិទ្ធិភាគីពាក់ព័ន្ធ និងគោលនយោបាយទំនាស់ផលប្រយោជន៍**

ដើម្បីធានាបាននូវសមភាពទីផ្សារ រាល់ប្រតិបត្តិការរបស់ហត្ថាកសិករ ជាមួយភាគីពាក់ព័ន្ធ យើងត្រូវស្នើសុំការអនុញ្ញាត ជាមុនពីក្រុមប្រឹក្សាភិបាល ឬអ្នកទទួលសិទ្ធិពីធនាគារមេ។ ប្រតិបត្តិការនេះមិនរាប់បញ្ចូលចំពោះឥណទានរបស់បុគ្គលិក ដែល មានចែងក្នុងគោលនយោបាយ ឥណទានរបស់បុគ្គលិកនោះទេ។

យោងទៅតាមគោលនយោបាយទំនាស់ផលប្រយោជន៍បុគ្គលិកទាំងអស់ត្រូវតែរាយការណ៍ពីសកម្មភាពដូចខាងក្រោមជាលាយលក្ខណ៍អក្សរទៅអ្នកគ្រប់គ្រង និងនាយកដ្ឋានប្រតិបត្តិតាម៖

(1) គ្រប់សកម្មភាពខាងក្រៅ មិនថាផលប្រយោជន៍ហិរញ្ញវត្ថុ ឬទំនាក់ទំនងដែលអាចបណ្តាលឲ្យ មានទំនាស់ផលប្រយោជន៍ ឬការលេចឡើងនូវទំនាស់ផលប្រយោជន៍ ។

(2) ការកាន់តំណែងនៅក្នុងស្ថាប័ន ដែលស្វែងរកប្រាក់ចំណេញ ឬមិនស្វែងរកប្រាក់ចំណេញ ឬក្រុម ហ៊ុនបុត្រសម្ព័ន្ធ ជាពិសេសប្រសិនបើស្ថាប័នដែលមានទំនាក់ទំនងជាមួយហត្ថាកសិករ ឬ អាចរំពឹងទុកថាទទួលជំនួយពី ហត្ថាកសិករ ក្នុងពេលដែលកំពុងបម្រើការងារ ។

(3) សមាជិកគ្រួសារដែលបម្រើការងារឲ្យហត្ថាកសិករ ឬក្រុមហ៊ុននៅក្នុងក្រុមអាជីវកម្មហិរញ្ញវត្ថុនៃក្រុងស្រី ។

បុគ្គលិកណាដែលបំពានទៅលើគោលនយោបាយនេះ នឹងត្រូវទទួលរងនូវពិន័យ ដោយយោងទៅតាមគោលការណ៍ផ្ទៃក្នុងរបស់ហត្ថាកសិករ និងអាចចាត់ទុកថាជាបទល្មើសដែលស្ថិតនៅក្រោមច្បាប់ បទប្បញ្ញត្តិ ឬលក្ខខណ្ឌតម្រូវដែលពាក់ព័ន្ធផ្សេងទៀត ។

# ផ្នែកទី ៤: ព័ត៌មានអំពីការជួញដូរមូលបត្រ

## ១-ព័ត៌មានអំពីមូលបត្រកម្មសិទ្ធិ

| ឈ្មោះមូលបត្របំណុល | THE FIRST CAMBODIAN CORPORATE BOND NO.1 |
|---|---|
| អក្សរកូដមូលបត្របំណុល | KH20000718B4 |
| ចំណាត់ថ្នាក់នៃមូលបត្របំណុល | សញ្ញាបណ្ណអាជីវកម្ម |
| តម្លៃចារឹកក្នុងមួយឯកតាតាមមូលបត្របំណុល | ១00,000 រៀល |
| ថ្លៃលក់ក្នុងមួយឯកតាតាមមូលបត្របំណុល | ១00,000 រៀល |
| បរិមាណមូលបត្រសរុបទាំងអស់ដែលកំពុងធ្វើចរាចរលើទីផ្សារ | ១,២00,000 |
| មូលធនូបនីយកម្មទីផ្សារ | ១២0,000,000,000 រៀល |
| ឈ្មោះទីផ្សារមូលបត្រប្រតិស្រុត | ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ០៥ ធ្នូ ២០១៨ |
| កាលបរិច្ឆេទនៃការចុះបញ្ជីលក់មូលបត្រ | ថ្ងៃទី០៥ ខែធ្នូ ឆ្នាំ ២០១៨ |

## ២-ថ្លៃ និងបរិមាណជួញដូរ

អំឡុងត្រីមាសទី១ឆ្នាំ ២០១៩ ពុំមានការជួញដូរមូលបត្របំណុលរបស់ ហត្ថាកសិករ ទេ។

## ផ្នែកទី ៥: របាយការណ៍សវនកម្មរបស់សវនករផ្ទៃក្នុងលើការត្រួតពិនិត្យផ្ទៃក្នុង

**កម្មវត្ថុសវនកម្ម**

ជំនួសមុខឱ្យគណៈកម្មាធិការសវនកម្មនៃក្រុមប្រឹក្សាភិបាល និងក្រុមប្រឹក្សាភិបាល បានធ្វើសវនកម្មលើសកម្មភាពគ្រប់គ្រងប្រតិបត្តិការ សកម្មភាពហិរញ្ញវត្ថុ និងសកម្មភាពផ្សេងៗទៀតដែលទាក់ទងនឹងប្រតិបត្តិការរបស់ហត្ថាកសិករ ដើម្បីធ្វើឱ្យប្រាកដថាៈ

- មុខងារអាជីវកម្ម/នាយកដ្ឋាននីមួយៗមានប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងបានល្អប្រសើរ និងអនុវត្តតាមបទបញ្ញាផ្ទៃក្នុង គោលការណ៍ និង នីតិវិធីរបស់ហត្ថាកសិករ។
- ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងមានភាពរឹងមាំ និងការគ្រប់គ្រងហានិភ័យមានប្រសិទ្ធិភាព។
- ការប្រើប្រាស់ធនធានឱ្យមានប្រសិទ្ធភាពនិងឱ្យមានលក្ខណៈសេដ្ឋកិច្ច។
- ការកត់ត្រាប្រតិបត្តិការនិងធ្វើរបាយការណ៍ហិរញ្ញវត្ថុមានភាពត្រឹមត្រូវ។
- ចំណុចខ្វះខាតនៃប្រតិបត្តិការប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងការគ្រប់គ្រងហានិភ័យត្រូវបានធ្វើការកែលម្អរឲ្យមានភាពរឹងមាំនិងល្អ ប្រសើរ។
- ការប្រតិបត្តិតាមក្បួនច្បាប់ និងតម្រូវការរបស់ធនាគារជាតិ ភាគទុនិក និងអ្នកវិនិយោគ។

**វិសាលភាពសវនកម្ម**

- សកម្មភាពធានាគុណភាព
  - ការវាយតម្លៃភាពគ្រប់គ្រាន់និងប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង
  - អនុលោមតាមគោលការណ៍ បទប្បញ្ញត្តិ និងច្បាប់។
  - ការវាយតម្លៃភាពគ្រប់គ្រាន់ និងប្រសិទ្ធិភាពនៃប្រព័ន្ធគ្រប់គ្រងហានិភ័យ។
  - ការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធផល ប្រសិទ្ធភាព និងមានលក្ខណៈសេដ្ឋកិច្ច។
  - ការសម្រេចបាននូវគោលបំណង និងគោលដៅ។

- សកម្មភាពពិគ្រោះយោបល់

សវនករត្រូវមានចំណេះដឹង និងការយល់ដឹងអំពីហានិភ័យ និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ហើយអាចយកចំណេះដឹងនិង បទពិសោធន៍របស់ខ្លួននៃសកម្មភាពធានាគុណភាពដើម្បីផ្តល់អត្ថប្រយោជន៍ជូនក្រុមហ៊ុនតាមរយៈការផ្តល់អនុសាសន៍ និងប្រឹក្សា តាមមុខងារផ្សេងៗនៃប្រតិបត្តិការរបស់ហត្ថាកសិករ។

**សង្ខេបរបាយការណ៍**

ចាប់ពីខែមករា ដល់ខែមីនា ឆ្នាំ ២០១៩ អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុងចុះធ្វើសវនកម្មបានចំនួន ២១ ការិយាល័យសាខា និង០៤នាយកដ្ឋាន។ ក្នុងអំឡុងពេលធ្វើសវនកម្មយើងបានរកឃើញនូវរបកគំហើញសំខាន់ៗ ដែលត្រូវបានសង្ខេបដូចខាងក្រោមៈ

| **សវនកម្មលើការិយាល័យកណ្ដាលពីសវនករផ្ទៃក្នុង** | |
|---|---|
| របកគំហើញ | អនុសាសន៍ពីសវនកម្មផ្ទៃក្នុង |
| ១. ព័ត៌មានស្តង់ដានៃតម្លៃដី និងផ្ទះនៅក្នុងក្រុងភ្នំពេញ មិនត្រូវបានផ្ទៀងផ្ទាត់ ឬប្រើប្រាស់ដោយបុគ្គលិកនៃនាយកដ្ឋានអនុម័ត ឥណទាន ដើម្បីផ្ទៀបជាមួយនឹងការវាយតម្លៃទ្រព្យរបស់អតិថិជន។<br>២. ឯកសារ និងលក្ខខ័ណ្ឌផ្សេងៗ ដែលតម្រូវដោយគណៈកម្មាធិការឥណទាន និងអនុគណៈកម្មាធិការឥណទានមិនត្រូវបាន ត្រួតពិនិត្យឱ្យបានត្រឹមត្រូវ។<br>៣. មិនមានអ្នកអនុម័តនៅលើការកត់ត្រា និងការផ្លាស់ប្តូរទិន្នន័យនៅក្នុងប្រព័ន្ធធនធានមនុស្ស។<br>៤. ការស្នើសុំកាតការងាររបស់បុគ្គលិកមិនត្រូវបានដាក់ជូនក្រសួងទទួលបន្ទុកវិស័យការងារនៅក្នុងរយៈពេល២៩ថ្ងៃចាប់ពី កាលបរិច្ឆេទនៃការចូលបម្រើការងាររបស់បុគ្គលិក។<br>៥. របាយការណ៍បំប្រែបំរួលបុគ្គលិកមិនត្រូវបានត្រួតពិនិត្យនិងប្រកាសឱ្យបានទាន់ពេលវេលាទៅក្រសួងទទួលបន្ទុកវិស័យការងារនិងបុគ្គលិកដែលធ្វើការនៅថ្ងៃឈប់សម្រាកប្រចាំសប្តាហ៍មិនអនុវត្តតាមការអនុម័តការស្នើសុំពន្យារពេលធ្វើការប្រចាំសប្តាហ៍។<br>៦. រយៈពេលនៃការជ្រើសរើសបុគ្គលិកមិនត្រូវបានបញ្ចប់ក្នុងរយៈពេល ៧៥ ថ្ងៃ។<br>៧. ដាក់ពាក្យបណ្តឹងទៅតុលាការ ដោយមិនមានការអនុម័តត្រឹមត្រូវពីអ្នកមានសិទ្ធិ។<br>៨. របាយការណ៍លើករណីប្តឹងទៅតុលាការគួបសរុបប្រចាំខែ មិនបានផ្ញើរជូនទៅថ្នាក់គ្រប់គ្រងដើម្បីជ្រាបជាព័ត៌មាន។<br>៩. ម្ចាស់ផ្តល់ប្រាក់កម្ចីជូនហត្ថាកសិករមួយចំនួន មិនត្រូវបានធ្វើការត្រួតពិនិត្យនៅក្នុងបញ្ជីខ្មៅ មុនពេលចុះហត្ថលេខាលើកិច្ច ព្រមព្រៀងប្រាក់កម្ចី។ | ១. នាយកអនុម័តឥណទានគួរតែធ្វើការត្រួតពិនិត្យតម្លៃស្តង់ដាដី និងផ្ទះនៅក្នុងក្រុងភ្នំពេញនៅក្នុងការវាយតម្លៃទ្រព្យធានា សម្រាប់វាយតម្លៃប្រាក់កម្ចី។<br>២. នាយកអនុម័តឥណទានគួរចាត់តាំង និងពង្រឹងលើបុគ្គលិកដើម្បីធ្វើការតាមដានជាប់ជាប្រចាំលើតម្រូវការឯកសារ និងលក្ខ ខណ្ឌដែលតម្រូវដោយគណៈកម្មាធិការឥណទានរហូតទាល់តែបញ្ហាត្រូវបានបិទជាមួយនឹងសាខា។<br>៣. នាយកជ្រើសរើសបុគ្គលិកនឹងធ្វើការជាមួយនាយកប្រព័ន្ធធនាគារស្នូលនិងសូលូសិនដើម្បីបង្កើតមុខងារផ្សេងគ្នានៃអ្នកប្រើ ប្រាស់និងអ្នកអនុម័តនៅក្នុងប្រព័ន្ធ។<br>៤. នាយកដ្ឋានជ្រើសរើសបុគ្គលិកគួរតែធ្វើបច្ចុប្បន្នភាពលើគោលនយោបាយធនធានមនុស្ស និងពង្រឹងលើបុគ្គលិកដើម្បីធ្វើការ បញ្ជូនសំណើរសុំសៀវភៅការងារអំឡុងពេល២០ថ្ងៃ នៃថ្ងៃចូលបម្រើការងាររបស់បុគ្គលិក។<br>៥. នាយកជ្រើសរើសបុគ្គលិកគួរតែរៀបចំរបាយការណ៍ប្រកាស់ចលនាបុគ្គលិកជូនក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈឱ្យបានទាន់ពេលវេលា។<br>៦. នាយកជ្រើសរើសបុគ្គលិកគួរតែបង្កើតឧបករណ៍ត្រួតពិនិត្យលើរបាយការណ៍ប្រកាសចលនាបុគ្គលិកដោយការិយាល័យសាខា។<br>៧. នាយកជ្រើសរើសបុគ្គលិកគួរតែតាមដានលើសំណើសុំព្យួរថ្ងៃឈប់សម្រាកប្រចាំសប្តាហ៍និងមិនត្រូវអនុញ្ញាតិឱ្យពួកគាត់ ធ្វើការលើសពីពីរថ្ងៃក្នុងមួយខែនិងធ្វើការនៅចុងសប្តាហ៍ជាប់ៗគ្នាហើយនឹងធ្វើការទំនាក់ទំនងលើការអនុម័តស្នើសុំព្យួរ<br>a. ថ្ងៃឈប់សម្រាកប្រចាំសប្តាហ៍ជាមួយនឹងនាយកដ្ឋានដែលពាក់ព័ន្ធ។<br>៨. នាយកជ្រើសរើសបុគ្គលិកគួរពិចារណាធ្វើបច្ចុប្បន្នភាពគោលនយោបាយនិងនីតិវិធីជ្រើសរើសបុគ្គលិកត្រង់ចំណុចពេលវាលានៃការជ្រើសរើសបុគ្គលិក។<br>៩. នាយកដោះស្រាយវិវាទត្រូវធ្វើការស្នើសុំអនុម័តពីអ្នកមានសិទ្ធិឡើងវិញនឹងពង្រឹងបុគ្គលិកលើការត្រួតពិនិត្យភាពគ្រប់គ្រាន់នៃឯកសារដាក់ពាក្យបណ្តឹងហើយនឹងប្រាកដថាពាក្យបណ្តឹងត្រូវបានអនុម័តនិងត្រូវបានផ្តល់អនុមសាសន៍មុនពេលដាក់ពាក្យ បណ្តឹងទៅតុលាការ។<br>១០. នាយកដោះស្រាយវិវាទគួរតែរៀបចំនិងរបាយការណ៍លើករណីប្តឹងទៅតុលាការគួបសរុបប្រចាំខែជូនទៅថ្នាក់គ្រប់គ្រងឱ្យបានទៀងទាត់។<br>១១. នាយិការតនាភិបាលគួរតែពង្រឹងលើការអនុវត្តន៍ការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មដោយត្រូវធ្វើសំណើរសុំនាយិកាប្រតិបត្តិតាមផែនបញ្ជីខ្មៅមុនពេលចុះកិច្ចព្រមព្រៀងប្រាក់កម្ចីជាមួយម្ចាស់ប្រាក់កម្ចីនិងនាយិការតនាភិបាលគួរតែផែនបញ្ជីខ្មៅឡើង វិញសម្រាប់ម្ចាស់ផ្តល់ប្រាក់កម្ចីដែលបានបង្ហាញនៅក្នុងរបាយការណ៍របកគំហើញសវនកម្ម។ |

| **សវនកម្មលើសាខាពីសវនករផ្ទៃក្នុង** | |
|---|---|
| របកគំហើញ | អនុសាសន៍ពីសវនកម្មផ្ទៃក្នុង |
| ១. ការគណនាផលធៀបលទ្ធភាពសងរបស់អតិថិជនមិនត្រឹមត្រូវ និងការពិនិត្យ ព័ត៌មានបំណុលរបស់អតិថិជនក្នុងរបាយការណ៍ CBC។<br>២. អនុម័តអត្រាការប្រាក់និងកម្រៃសេវាឥណទានមិនបានត្រឹមត្រូវ តាមសេចក្ដីសម្រេច និង មិនបានអនុវត្តតាមចំណារអនុម័ត របស់គណៈកម្មាធិការថ្នាក់គ្រប់គ្រង។<br>៣. បើកគណនីឥណទានដោយកត់ត្រាអត្រាការប្រាក់មិនបានត្រឹមត្រូវតាមការអនុម័ត និងទូទាត់កម្រៃសេវា CBC ពីអតិថិជនមិនបានគ្រប់ចំនួន។<br>៤. កង្វះខាតក្នុងការអនុវត្តគោលនយោបាយឬគោលការណ៍ប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងវិធានទទួល ស្គាល់អតិថិជន (KYC/UDD) ដូចជា៖មិនបានផ្ទៀ ងផ្ទាត់ឈ្មោះអតិថិជនជាមួយនឹងបញ្ជីខ្មៅ និងមិនបានស្នើសុំអត្តសញ្ញាណ ប័ណ្ណសម្រាប់ប្រតិបត្តិការដាក់ប្រាក់សន្សំជំនួសធំជាង១០ ពាន់ដុល្លារ។<br>៥. បើកគណនីសន្សំជូនអតិថិជនដោយមិនមានការរៀបចំទម្រង់ FATCA។<br>៦. កង្វះខាងចំពោះការគ្រប់គ្រងសាច់ប្រាក់ដូចជា៖ មិនបានរាប់សាច់ប្រាក់នៅក្នុងទូដែកត្រៀមបម្រុង សម្រាប់ការរាប់សាច់ប្រាក់ ប្រចាំសប្ដាហ៍ និងឥតព្រៀងទុក និងមិនបានរៀបចំសំណើសុំរក្សាសាច់ប្រាក់ទុកលើសគោលការណ៍ (០២ ថ្ងៃ)។ | ១. a.នាយកសាខាត្រូវរៀបចំសំណើទៅនាយកដ្ឋានលក់ឥណទានដើម្បីសុំការអនុម័តសម្រាប់ផលធៀបលទ្ធភាពសងអតិថិជន ហើយនាយកដ្ឋានលក់ឥណទានណែនាំដល់នាយកសាខាក្នុងការចាត់ឱ្យបុគ្គលិកពាក់ព័ន្ធរៀបចំកិច្ចព្រមព្រៀងចែករំលែកព័ត៌មានដែលសមស្របសម្រាប់អ្នកបញ្ចាំជំនួសនិងត្រួតពិនិត្យ CBC អ្នកខ្ចី។<br>b.នាយកដ្ឋានលក់ឥណទានត្រូវពង្រឹងប្រតិបត្តិករឥណទានទាក់ទងនឹងការត្រួតពិនិត្យ CBCនិងការរៀបចំកិច្ចព្រមព្រៀងចែករំលែកព័ត៌មាន។<br>២. a.នាយកដ្ឋានលក់ឥណទានត្រូវណែនាំនាយកសាខាចាត់ឱ្យបុគ្គលិកពាក់ព័ន្ធទាក់ទងអតិថិជន ដើម្បីស្នើសុំឯកសារ និងលក្ខខណ្ឌតម្រូវបន្ថែម។ បើមិនបានត្រូវស្នើទៅ MCC/CSD ដើម្បីអនុម័ត។<br>b.នាយកដ្ឋានគ្រប់គ្រងប្រសិទ្ធភាពសាខាត្រូវពន្លឿនបង្កើតប្រព័ន្ធតាមដានសម្រាប់ផ្ទៀងផ្ទាត់ឯកសារតម្រូវដោយ MCC។<br>៣. នាយកដ្ឋានលក់ឥណទានត្រូវពង្រឹងនាយកសាខា ប្រធានឥណទាន និងប្រធានគណនេយ្យ និងត្រូវណែនាំនាយកសាខាចាត់ឱ្យ បុគ្គលិកពាក់ព័ន្ធស្នើសុំកម្រៃសេវាបន្ថែមនិងឯកសារគាំទ្រពីអតិថិជននិងចាត់ឱ្យប្រធានគណនេយ្យរៀបចំស្នើសុំទៅកាន់នាយក ដ្ឋានលក់ឥណទាន និងនាយកដ្ឋានហិរញ្ញវត្ថុរៀបចំតារាងសងប្រាក់ថ្មីតាមអត្រាការប្រាក់ដែលបានអនុម័ត។<br>៤. នាយកដ្ឋានប្រតិបត្តិតាមគួរតែណែនាំនាយកសាខាឱ្យចាត់បុគ្គលិកពាក់ព័ន្ធចូលត្រួតពិនិត្យឈ្មោះអតិថិជនទាំងអស់នេះបន្ថែម ករណីមានឈ្មោះអតិថិជនក្នុងបញ្ជីខ្មៅត្រូវរាយការណ៍ទៅនាយកដ្ឋានប្រតិបត្តិតាមដើម្បីមានជាចំណាត់ការនិងត្រូវទាក់ទងទៅអតិថិជនដើម្បីស្នើសុំថតចម្លងអត្តសញ្ញាណប័ណ្ណមកភ្ជាប់គ្រប់គ្រាន់ឡើងវិញ។<br>៥. a.នាយកដ្ឋានប្រតិបត្តិតាមគួរណែនាំដល់នាយកសាខាដើម្បីចាត់តាំងឱ្យបុគ្គលិកទទួលខុសត្រូវទាក់ទងទៅអតិថិជនក្នុងការ ដើម្បីបំពេញទម្រង់ FATCA បន្ថែម និងត្រូវផ្ដល់ការណែនាំបន្ថែមលើការបំពេញទម្រង់បែបបទ FATCA នេះ។<br>b.នាយកដ្ឋានប្រតិបត្តិតាមគួរមានយន្តការសមស្របដើម្បីប្រាកដថាទម្រង់ FATCAត្រូវបានបំ ពេញបានគ្រប់គ្រាន់ចំពោះ ជនជាតិអាមេរិកក្នុងកំឡុងពេលបើកគណនីជូនអតិថជន។<br>៦. នាយិការនាយកដ្ឋានប្រតិបត្តិការគួរតែតែទាក់ទងដោយផ្ទាល់ទៅកាន់នាយកសាខាពាក់ព័ន្ធ និងនាយកសាខាផ្សេងៗទៀតដើម្បីណែនាំឡើងវិញអំពីសេចក្ដីណែនាំស្ដីពីការគ្រប់គ្រងសាច់ប្រាក់ដែលទើបធ្វើបច្ចុប្បន្នភាពថ្មី (ជំនាន់ទី៤) ដើម្បីឱ្យពួកគាត់បាន យល់ច្បាស់លាស់។ |

**សេចក្តីសន្និដ្ឋាន**

ហត្ថាកសិករជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមួយដែលមានរចនាសម្ព័ន្ធពេញលេញចាប់ពីកម្រិតក្រុមប្រឹក្សាភិបាល និងថ្នាក់គ្រប់គ្រង ព្រមទាំង មានការគ្រប់គងហានិភ័យនិងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងល្អ។ហត្ថាកសិករបានអនុវត្តការងារប្រចាំថ្ងៃបានល្អទៅតាមគោលនយោបាយនិងនីតិវិធីផ្ទៃក្នុងរបស់ខ្លួន តាមក្បួនច្បាប់ និងបទប្បញ្ញត្តិនានា។ ទោះជាយ៉ាងណា ក៏នូវមានចំណុចខ្វះចន្លោះមួយចំនួនដូចបានរៀបរាប់នៅ ក្នុងរបកគំហើញខាងលើ (ចំណុចទី៤) ដែលត្រូវធ្វើការកែលម្អដើម្បីឱ្យការងារកាន់តែមានភាពល្អប្រសើរ ព្រមទាំងដើម្បីឲ្យប្រព័ន្ធត្រួតពិនិត្យ ផ្ទៃក្នុង និងប្រព័ន្ធគ្រប់គ្រងហានិភ័យមានប្រសិទ្ធភាពខ្ពស់។

ប្រតិបត្តិករត្រូវអនុវត្តឱ្យបាននូវចំណុចខ្វះចន្លោះដែលសវនករផ្ទៃក្នុងបានរកឃើញនិងកែលម្អរបកគំហើញទៅតាមអនុសាសន៍ដែលបានផ្តល់ជូនដោយសវនករផ្ទៃក្នុង។ សវនករផ្ទៃក្នុងនឹងនឹងធ្វើការតាមដានរាល់របកគំហើញ និងអនុសាសន៍ជារៀងរាល់ខែ ព្រមទាំង ធ្វើរបាយការណ៍ជូនគណៈកម្មាធិការសវនកម្មនៃក្រុមប្រឹក្សាភិបាល និងក្រុមប្រឹក្សាភិបាលរៀងរាល់ខែ។

គណៈកម្មាធិការសវនកម្មផ្ទៃក្នុង

លោក ឌី ដាវុឌ្ឍ
ប្រធានគណៈកម្មាធិការសវនកម្ម
ថ្ងៃទី៖ 28/06/2019

អគ្គនាយកសវនកម្មផ្ទៃក្នុង

លោក រស់ វ៉ុល
អគ្គនាយកសវនកម្មផ្ទៃក្នុង
ថ្ងៃទី៖ 28/06/2019

## ផ្នែកទី ៦ : របាយការណ៍ហិរញ្ញវត្ថុដែលបានពិនិត្យឡើងវិញដោយសវនករឯករាជ្យ

**របាយការណ៍របស់ក្រុមប្រឹក្សាភិបាល**

របាយការណ៍ហិរញ្ញវត្ថុដែលភ្ជាប់មកជាមួយរបស់ ហត្ថាកសិករ (ហៅកាត់ថា "ក្រុមហ៊ុន" ឬ "អេច ខេ អិល") បានបង្ហាញភាពត្រឹមត្រូវ នូវស្ថានភាពហិរញ្ញវត្ថុនាថ្ងៃទី៣១ ខែមីនា ឆ្នាំ ២០១៩ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់ សម្រាប់រយៈពេល៣ខែដែលបានបញ្ចប់ ដោយអនុលោមទៅតាមស្តង់ដារគណនេយ្យអន្តរជាតិនៃកម្ពុជា លេខ ៣៤ "របាយការណ៍ហិរញ្ញវត្ថុ ចន្លោះពេល"។ ត្រឹមកាលបរិច្ឆេទចេញផ្សាយរបាយការណ៍នេះ ក្រុមប្រឹក្សា ភិបាលជឿជាក់ថា ក្រុមហ៊ុនមានលទ្ធភាពគ្រប់គ្រាន់ក្នុងការទូទាត់បំណុលនៅពេលដល់កំណត់សង។

ចុះហត្ថលេខាក្នុងនាមក្រុមប្រឹក្សាភិបាលៈ

លោក ហួត អៀងតុង
ប្រធានអគ្គនាយក
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី ៖ 28 ខែ មិថុនា 2019

# ហត្ថាកសិករ
# របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ
# នាថ្ងៃទី៣១ ខែមីនា ឆ្នាំ ២០១៩

| | នាថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៩ | | នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ | | នាថ្ងៃទី១ ខែមករា ឆ្នាំ២០១៨ | |
|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ទ្រព្យសកម្ម | | | | | | |
| សាច់ប្រាក់ក្នុងដៃ | ៤០,៤១៦,៣៨៩ | ១៦២,២៧១,៨០២ | ៣៧,២១១,១៥៥ | ១៤៩,៥១៤,៤២១ | ៩,៩២៣,៦០៤ | ៤០,០៦១,៥៨៩ |
| សមតុល្យនៅធនាគារជាតិនៃកម្ពុជា | ៦៣,៣៥៦,៧៤២ | ២៥៤,៣៧៧,៣១៩ | ៧៧,៦០២,១៨៨ | ៣១១,៨០៥,៥៩១ | ៤១,២៦៤,១៣៦ | ១៦៦,៥៨៣,៣១៧ |
| សមតុល្យនៅធនាគារនានា | ៣៩,៣៨៧,២៧៨ | ១៥៨,១៣៩,៩២១ | ៣៩,៥៩៤,៣១៥ | ១៥៩,០៨៩,៩៥៨ | ៥៧,០៣៥,៥០៥ | ២៣០,២៥២,៣៣៤ |
| ឥណទានផ្តល់ដល់អតិថិជន | ៨១០,១៥១,៦៨១ | ៣,២៥២,៧៥៨,៩៩៩ | ៧៤១,៨៣៩,០២៨ | ២,៩៨០,៧០៩,២១៥ | ៥៦៤,២០២,៣១៥ | ២,២៧៧,៦៨៤,៧៤៦ |
| វិនិយោគលើមូលបត្រ | ២៧,៨២៦ | ១១១,៧២១ | ២០,០០០ | ៨០,៣៦០ | ២០,០០០ | ៨០,៧៤០ |
| ទ្រព្យសម្បត្តិ និងបរិក្ខារ | ៤,១៣២,៣៨៤ | ១៦,៥៩១,៥២២ | ៤,១៤៨,៦៣៤ | ១៦,៦៦៩,២១១ | ៣,៩៥៨,៩៨៤ | ១៥,៩៨២,៤១៨ |
| សិទ្ធិក្នុងការប្រើទ្រព្យសកម្ម | ១២,៥២០,៣៥២ | ៥០,២៦៩,២១៣ | ១២,៧៨៨,២៦៥ | ៥១,៣៨៣,២៤៩ | ១៣,២២៥,៧១៧ | ៥៣,៣៩២,២២០ |
| ទ្រព្យសកម្មអរូបី | ១,២៣៣,០៨៦ | ៤,៩៥០,៨៤០ | ៨៣៥,៩១១ | ៣,៣៥៨,៦៩០ | ៦១១,៧២៦ | ២,៤៦៩,៥៣៨ |
| ពន្ធពន្យារជាទ្រព្យសកម្ម - សុទ្ធ | ៣,៣៣១,៣៣៧ | ១៣,៣៧៥,៣១៨ | ៣,១០០,២១២ | ១២,៤៥៦,៦៥២ | ១,៨៧៦,៦៣៩ | ៧,៥៧៥,៩៩២ |
| ទ្រព្យសកម្មផ្សេងៗ | ៨,៧២៨,៥៤៧ | ៣៥,០៤៥,១១៦ | ៧,៩៣៨,៨៧៧ | ៣១,៨៩៨,៤០៨ | ៧,៤៧៧,៨១៨ | ៣០,១៨៧,៩៥១ |
| **សរុបទ្រព្យសកម្ម** | **៩៨៣,២៨៥,៦២២** | **៣,៩៤៧,៨៩១,៧៧១** | **៩២៥,០៧៨,៥៨៥** | **៣,៧១៦,៩៦៥,៧៥៥** | **៦៩៩,៥៩៦,៤៤៤** | **២,៨២៤,២៧០,៨៤៥** |

# ហត្ថាកសិករ
# របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ
# នាថ្ងៃទី៣១ ខែមីនា ឆ្នាំ ២០១៩

| | នាថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៩ | | នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ | | នាថ្ងៃទី ១ ខែមករា ឆ្នាំ២០១៨ | |
|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| បំណុល | | | | | | |
| ប្រាក់បញ្ញើរបស់អតិថិជន | ៥២៦,៥៦៤,៥២៩ | ២,១១៤,១៥៦,៥៨៤ | ៤៩១,៣៥៣,៣៩០ | ១,៩៧៤,២៥៧,៩២១ | ៣៧៥,៨២២,៨៦៧ | ១,៥១៧,១៩៦,៩១៤ |
| មូលបត្របំណុល | ២៩,៩៩៧,៤០៩ | ១២០,៤៣៩,៥៩៧ | ២៩,៣២៥,២៥២ | ១១៧,៨២៨,៨៦៣ | - | - |
| ប្រាក់កម្ចី | ២១២,៧២៩,៥៨៨ | ៨៥៤,១០៩,២៩៦ | ១៩១,៧២៥,១៥៨ | ៧៧០,៣៥១,៦៨៥ | ១៧៥,៤៤៨,៩៩២ | ៧០៨,២៨៧,៥៨១ |
| អនុបំណុល | ២២,៤៤៧,៧៩២ | ៩០,១២៧,៨៨៥ | ២៣,២៣៦,២៩៦ | ៩៣,៣៦៣,៤៣៧ | ២៥,២៥៨,២៩៩ | ១០១,៩៦៧,៧៥៣ |
| និសន្សន្ទសម្រាប់ទប់ស្កាត់ហានិភ័យ | ៤១៧,០៤៧ | ១,៦៧៤,៤៤៤ | ២៧,៧៩៤ | ១១១,៦៧៦ | ៣៥៨,០២០ | ១,៤៤៥,៣២៧ |
| បំណុលពន្ធលើប្រាក់ចំណេញ | ១,៥៦៦,២២១ | ៦,២៨៨,៣៧៧ | ៤,៨៦២,៥៤២ | ១៩,៥៣៧,៦៩៤ | ៣,៥១០,០០៩ | ១៤,១៦៩,៩០៦ |
| បំណុលភតិសន្យា | ១២,៩៩៣,៨២៧ | ៥២,១៧០,២១៥ | ១៣,១៧២,៤៤៨ | ៥២,៩២៦,៨៩៦ | ១៣,១០១,៦០៦ | ៥២,៨៩១,១៨៣ |
| សំវិធានធន | ៣,៧៤៥ | ១៥,០៣៦ | ៣,៥៩៩ | ១៤,៤៦១ | ៤,៧៣១ | ១៩,០៩៩ |
| បំណុលផ្សេងៗ | ៤,៣០៥,៣៧៨ | ១៧,២៨៦,០៩៣ | ៥,១២៧,៧៥៣ | ២០,៦០៣,៣១២ | ៣,៨៤១,២៩៣ | ១៥,៥០៧,៣០០ |
| **សរុបបំណុល** | **៨១១,០២៥,៥៣៦** | **៣,២៥៦,២៦៧,៥២៧** | **៧៥៨,៨៣៤,២៣២** | **៣,០៤៨,៩៩៥,៩៤៥** | **៥៩៧,៣៤៥,៨១៧** | **២,៤១១,៤៨៥,០៦៣** |
| មូលធន | | | | | | |
| ដើមទុន | ៧៥,០០០,០០០ | ៣០១,១២៥,០០០ | ៧៥,០០០,០០០ | ៣០១,៣៥០,០០០ | ៣០,០០០,០០០ | ១២១,១១០,០០០ |
| បុព្វលាភភាគហ៊ុន | ១៩,០៨២,៥០២ | ៧៦,៦១៦,២៤៦ | ១៩,០៨២,៥០២ | ៧៦,៦៧៣,៤៩៣ | ១៩,០៨២,៥០២ | ៧៧,០៣៦,០៦១ |
| ទុនបម្រុង | ៥,៣២២,១៩០ | ២១,៣៦៨,៥៩៣ | ៤,៣៨៩,១៨៧ | ១៧,៦៣៥,៧៥៣ | ២,៧២១,១០១ | ១០,៩៨៥,០៨៥ |
| ប្រាក់ចំណេញរក្សាទុក | ៧២,៨៥៥,៣៩៤ | ២៩២,៥១៤,៤០៥ | ៦៧,៧៧២,៦៦៤ | ២៧២,៣១០,៥៦៤ | ៥០,៤៤៧,០២៤ | ២០៣,៦៥៤,៦៣៦ |
| **សរុបមូលធន** | **១៧២,២៦០,០៨៦** | **៦៩១,៦២៤,២៤៤** | **១៦៦,២៤៤,៣៥៣** | **៦៦៧,៩៦៩,៨១០** | **១០២,២៥០,៦២៧** | **៤១២,៧៨៥,៧៨២** |
| **សរុបបំណុល និងមូលធន** | **៩៨៣,២៨៥,៦២២** | **៣,៩៤៧,៨៩១,៧៧១** | **៩២៥,០៧៨,៥៨៥** | **៣,៧១៦,៩៦៥,៧៥៥** | **៦៩៩,៥៩៦,៤៤៤** | **២,៨២៤,២៧០,៨៤៥** |

# ហត្ថាកសិករ
# របាយការណ៍ចំណេញខាត និងចំណូលបន្ទាប់បន្សំផ្សេងៗ
# សម្រាប់រយៈពេល ៣ ខែ គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ ២០១៩

| | សម្រាប់រយៈពេល ៣ ខែ គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៩ | | សម្រាប់រយៈពេល ៣ ខែ គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៨ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| | | | (មិនបានត្រួតពិនិត្យ និងធ្វើសវនកម្ម) | |
| ចំណូលពីការប្រាក់ | ៣១,៧៥២,៥៣១ | ១២៧,២០០,៦៣៩ | ២៥,៤១៨,៩២៩ | ១០១,៩៨០,៧៤៣ |
| ចំណាយលើការប្រាក់ | (១៣,៥១៩,៤៨៦) | (៥៤,១៥៩,០៦១) | (១០,២៧៤,២៣៨) | (៤១,២២០,២៤៣) |
| **ចំណូលសុទ្ធពីការប្រាក់** | **១៨,២៣៣,០៤៥** | **៧៣,០៤១,៥៧៨** | **១៥,១៤៤,៦៩១** | **៦០,៧៦០,៥០០** |
| ចំណូលពីកម្រៃជើងសារ | ១,២១៥,៩៧៩ | ៤,៨៧១,២១២ | ៥៥៤,៥៩២ | ២,២២៥,០២៣ |
| ចំណាយលើកម្រៃជើងសារ | (១៨២,០៦០) | (៧២៩,៣៣២) | (១៨៣,៧៣៣) | (៧៣៧,១៣៧) |
| **ចំណូលសុទ្ធពីកម្រៃជើងសារ** | **១,០៣៣,៩១៩** | **៤,១៤១,៨៨០** | **៣៧០,៨៥៩** | **១,៤៨៧,៨៨៦** |
| ការខាតសុទ្ធពីឧបករណ៍ហិរញ្ញវត្ថុផ្សេងៗវាស់វែង តាម FVTPL | (៣៨៩,២៥៣) | (១,៥៥៩,៣៤៨) | (៨៥,៩១២) | (៣៤៤,៦៧៩) |
| ចំណូលផ្សេងៗ | ១៧៨,៥១៥ | ៧១៥,១៣១ | ២៤២,៣៤៧ | ៩៧២,២៩៦ |
| ការខាតបង់សុទ្ធពីការធ្លាក់ចុះតម្លៃឧបករណ៍ហិរញ្ញវត្ថុ | (១៥៦,៦២៥) | (៦២៧,៤៤០) | (៧៣១,៣៧៥) | (២,៩៣៤,២៧៧) |
| ចំណាយបុគ្គលិក | (៧,៩៤០,៥៣៥) | (៣១,៨០៩,៧៨៣) | (៦,៧១៩,៨៦២) | (២៦,៩៦០,០៨៦) |
| ចំណាយរំលស់ | (១,៣១០,០៨៩) | (៥,២៤៨,២១៧) | (១,២១៨,៦៥៩) | (៤,៨៨៩,២៦០) |
| ចំណាយផ្សេងៗ | (១,៩១២,៤៦៨) | (៧,៦៦១,៣៤៧) | (១,៩៣៩,១៧១) | (៧,៧៧៩,៩៥៤) |
| **ប្រាក់ចំណេញមុនដកពន្ធ** | **៧,៧៣៦,៥០៩** | **៣០,៩៩២,៤៥៤** | **៥,០៦២,៩១៨** | **២០,៣១២,៤២៦** |
| ពន្ធលើប្រាក់ចំណេញ | (១,៧២០,៧៧៦) | (៦,៨៩៣,៤២៩) | (១,០៣២,៩៦៣) | (៤,១៤៤,២៤៨) |
| ប្រាក់ចំណេញក្នុងគ្រា | ៦,០១៥,៧៣៣ | ២៤,០៩៩,០២៥ | ៤,០២៩,៩៥៥ | ១៦,១៦៨,១៧៨ |
| ចំណូលបន្ទាប់បន្សំផ្សេងៗ | - | (១៥៧,៥៧៥) | - | (១,៩០២,៧៤០) |
| **សរុបប្រាក់ចំណេញក្នុងគ្រា** | **៦,០១៥,៧៣៣** | **២៣,៩៤១,៤៥០** | **៤,០២៩,៩៥៥** | **១៤,២៦៥,៤៣៨** |
| **ប្រាក់ចំណេញផ្ទាល់ របស់ម្ចាស់ហ៊ុន** | **៦,០១៥,៧៣៣** | **២៤,០៩៩,០២៥** | **៤,០២៩,៩៥៥** | **១៦,១៦៨,១៧៨** |
| **សរុបប្រាក់ចំណេញផ្ទាល់ របស់ម្ចាស់ហ៊ុន** | **៦,០១៥,៧៣៣** | **២៣,៩៤១,៤៥០** | **៤,០២៩,៩៥៥** | **១៤,២៦៥,៤៣៨** |

# ហត្ថាកសិករ
# របាយការណ៍បម្រែបម្រួលមូលធន
# សម្រាប់រយៈពេល ៣ ខែ គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ ២០១៩

| | មូលធនផ្ទាល់របស់ម្ចាស់ហ៊ុន | | | | |
|---|---|---|---|---|---|
| | ដើមទុន | បុព្វលាភភាគហ៊ុន | ទុនបម្រុង | ប្រាក់ចំណេញរក្សាទុក | សរុប |
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| **សម្រាប់រយៈពេល ៣ខែ គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៨** (មិនបានត្រួតពិនិត្យ និងធ្វើសវនកម្ម) | | | | | |
| នាថ្ងៃទី១ ខែមករា ឆ្នាំ២០១៨ | ៣០,០០០,០០០ | ១៩,០៨២,៥០២ | ២,៧២១,១០១ | ៥០,៤៤៧,០២៤ | ១០២,២៥០,៦២៧ |
| ប្រាក់ចំណេញក្នុងគ្រា | - | - | - | ៤,០២៩,៩៥៥ | ៤,០២៩,៩៥៥ |
| ប្រាក់ចំណូលបន្ទាប់បន្សំផ្សេងៗ | - | - | - | - | - |
| សរុបប្រាក់ចំណេញក្នុងគ្រា | - | - | - | ៤,០២៩,៩៥៥ | ៤,០២៩,៩៥៥ |
| ការផ្ទេរពីប្រាក់ចំណេញរក្សាទុកទៅទុនបម្រុងតាមបទប្បញ្ញត្តិ | - | - | ១,០១៣,១៦៩ | (១,០១៣,១៦៩) | - |
| នាថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៨ | ៣០,០០០,០០០ | ១៩,០៨២,៥០២ | ៣,៧៣៤,២៧០ | ៥៣,៤៦៣,៨១០ | ១០៦,២៨០,៥៨២ |
| **សមមូលជាពាន់រៀល** | **១២០,០០០,០០០** | **៧៦,៣៣០,០០៨** | **១៣,០៣៤,៣៤០** | **២១៥,៧៥៧,៩៨០** | **៤២៥,១២២,៣២៨** |
| **សម្រាប់រយៈពេល ៣ខែ គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៩** | | | | | |
| នាថ្ងៃទី១ ខែមករា ឆ្នាំ២០១៩ | ៧៥,០០០,០០០ | ១៩,០៨២,៥០២ | ៤,៣៨៩,១៨៧ | ៦៧,៧៧២,៦៦៤ | ១៦៦,២៤៤,៣៥៣ |
| ប្រាក់ចំណេញក្នុងគ្រា | - | - | - | ៦,០១៥,៧៣៣ | ៦,០១៥,៧៣៣ |
| ប្រាក់ចំណូលបន្ទាប់បន្សំផ្សេងៗ | - | - | - | - | - |
| សរុបប្រាក់ចំណេញក្នុងគ្រា | - | - | - | ៦,០១៥,៧៣៣ | ៦,០១៥,៧៣៣ |
| ការផ្ទេរពីប្រាក់ចំណេញរក្សាទុកទៅទុនបម្រុងតាមបទប្បញ្ញត្តិ | - | - | ៩៣៣,០០៣ | (៩៣៣,០០៣) | - |
| នាថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៩ | ៧៥,០០០,០០០ | ១៩,០៨២,៥០២ | ៥,៣២២,១៩០ | ៧២,៨៥៥,៣៩៤ | ១៧២,២៦០,០៨៦ |
| **សមមូលជាពាន់រៀល** | **៣០១,១២៥,០០០** | **៧៦,៦១៦,២៤៦** | **២១,២១១,០១៩** | **២៩២,៦៧១,៩៧៩** | **៦៩១,៦២៤,២៤៤** |

# ហត្ថាកសិករ
# របាយការណ៍លំហូរសាច់ប្រាក់
# សម្រាប់រយៈពេល ៣ ខែ គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ ២០១៩

| | សម្រាប់រយៈពេល ៣ ខែ គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៩ | | សម្រាប់រយៈពេល ៣ ខែ គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៨ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| | | | (មិនបានត្រួតពិនិត្យ និងធ្វើសវនកម្ម) | |
| លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ | | | | |
| ប្រាក់ចំណេញក្នុងគ្រា | ៦,០១៥,៧៣៣ | ២៣,៩៤១,៤៥០ | ៤,០២៩,៩៥៥ | ១៤,២៦៥,៤៣៨ |
| និយ័តភាព៖ | | | | |
| ចំណូលពីការប្រាក់សុទ្ធ | (១៨,២៣៣,០៤៥) | (៧៣,០៤១,៩៧៨) | (១៥,១៤៤,៦៩១) | (៦០,៧៦០,៥០០) |
| ភាគលាភពីមូលបត្រកម្មសិទ្ធិ វាស់វែងតាម FVOCI | (៧,៨៣៥) | (៣១,៣៨៧) | - | - |
| ការខាតបង់សុទ្ធពីការធ្លាក់ចុះតម្លៃ ឧបករណ៍ហិរញ្ញវត្ថុ | ១៥៦,៦២៥ | ៦២៧,៤៤០ | ៧៣១,៣៧៥ | ២,៩៣៤,២៧៧ |
| ចំណាយរំលស់ | ១,៣១០,០៨៩ | ៥,២៤៨,២១៧ | ១,២១៨,៦៥៩ | ៤,៨៨៩,២៦០ |
| ចំណាយបុគ្គលិកផ្សេងៗ | ៣០៣,៣១៦ | ១,២១៥,០៨៤ | ៣៨០,៦៩៧ | ១,៥២៧,៣៥៦ |
| ចំណេញពីការលក់ទ្រព្យសម្បត្តិ និងបរិក្ខារ | (៧៨) | (៣១២) | (១៨១) | (៧២៦) |
| ចំណាយពន្ធលើប្រាក់ចំណេញ | ១,៧២០,៧៧៦ | ៦,៨៩៣,៤២៩ | ១,០៣២,៩៦៣ | ៤,១៤៤,២៤៨ |
| **លំអៀងពីការប្តូររូបិយប័ណ្ណ ជាតុជារូបិយវត្ថុ** | **១៧៧,០៦៧** | **៧០៩,៣៣០** | **៤១៩,៥៦៥** | **១,៦៧៨,២៦០** |
| | (៨,៥៥៧,៣៥២) | (៣៤,៤៣៨,៣២៧) | (៧,៣៣១,៦៥៨) | (៣១,៣២២,៣៨៧) |
| បម្រែបម្រួលៈ | | | | |
| សមតុល្យនៅធនាគារជាតិនៃកម្ពុជា | (៣,១០៣,៣៤៧) | (១២,៤៣២,០០៨) | (១,៨០០,០០០) | (៧,២២១,៦០០) |
| ឥណទានផ្តល់ដល់អតិថិជន | (៦៩,០៥១,៧៥៤) | (២៧៦,៦២១,៣២៧) | (៥៥,៩០៤,៥២២) | (២២៤,៣០៤,៩៩០) |
| ទ្រព្យសកម្មផ្សេងៗ | (៦៧១,១៥២) | (២,៦៨៨,៦៣៥) | (៥០២,៨៥១) | (២,០១៧,៤៣៨) |
| និសន្សន្ទសម្រាប់ទប់ស្កាត់ហានិភ័យ | ៣៨៩,២៥៣ | ១,៥៥៩,៣៤៨ | ៦៦,៣២៦ | ២៦៦,១០០ |
| ប្រាក់បញ្ញើរបស់អតិថិជន | ៣៥,០៦៣,៩៧៦ | ១៤០,៤៦៦,២៨៨ | ១៧,០៣៨,៧៩១ | ៦៨,៣៥៩,៦២៩ |
| បំណុលផ្សេងៗ | (៨២២,៣៧៥) | (៣,២៩៤,៤៣៤) | (៩,៧៩០) | (៣៩,២៧៧) |
| សាច់ប្រាក់ប្រើប្រាស់ក្នុងប្រតិបត្តិការ | (៤៦,៧៥២,៧៥១) | (១៨៧,៤៤៩,០៩៥) | (៤៨,៤៤៧,៧០៤) | (១៩៦,២៧៩,៩៦៣) |
| ការប្រាក់បានទទួល | ៣១,៩៨៨,៥៤១ | ១២៨,១៤៦,០៩៥ | ២៥,៩៦៥,២៩៥ | ១០៤,១៧២,៧៦៤ |
| ការប្រាក់បានបង់ | (១០,១៨៦,២៧៤) | (៤០,៨០៦,២១៤) | (៩,៨០៧,១៩០) | (៣៩,៣៤៦,៤៤៦) |
| ពន្ធលើប្រាក់ចំណេញបានបង់ | (៥,២៤៨,២២២) | (២១,០២៤,៣៧៧) | (៣,៦៨៣,១០៣) | (១៤,៧៧៦,៦០៩) |
| **សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពប្រតិបត្តិការ** | **(៣០,១៩៨,៧០៦)** | **(១២១,១៣៣,៥៩១)** | **(៣៥,៩៧២,៧០២)** | **(១៤៦,២៣០,២៥៤)** |

# ហត្ថាកសិករ
# របាយការណ៍លំហូរសាច់ប្រាក់
# សម្រាប់រយៈពេល ៣ ខែ គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ ២០១៩

| | សម្រាប់រយៈពេល ៣ ខែ គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៩ | | សម្រាប់រយៈពេល ៣ ខែ គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៨ | |
|---|---|---|---|---|
| | **ដុល្លារអាមេរិក** | **ពាន់រៀល** | **ដុល្លារអាមេរិក** | **ពាន់រៀល** |
| លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ | | | (មិនបានត្រួតពិនិត្យ និងធ្វើសវនកម្ម) | |
| ការទិញទ្រព្យសម្បត្តិ និងបរិក្ខារ | (៥៣៥,១៧៩) | (២,១៤៣,៩២៧) | (៦១២,០៩៣) | (២,៤៥៥,៧១៧) |
| ការទិញទ្រព្យសកម្មអរូបី | (៤៤៥,៨៨៥) | (១,៧៨៦,២១៥) | - | - |
| សាច់ប្រាក់បានពីការលក់ទ្រព្យសម្បត្តិ និងបរិក្ខារ | ៥០០ | ២,០០៣ | ១៨៣ | ៧៣៤ |
| **សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុសកម្មភាពវិនិយោគ** | **(៩៨០,៥៦៤)** | **(៣,៩២៨,១៣៩)** | **(៦១១,៩១០)** | **(២,៤៥៤,៩៨៣)** |
| | | | | |
| លំហូរសាច់ប្រាក់ពីសកម្មភាពហិរញ្ញប្បទាន | | | | |
| សាច់ប្រាក់បានពីប្រាក់កម្ចី | ២៦,០៤៩,៣៦២ | ១០៤,៣៥៣,៧៤៤ | ៦៨,៥៦៦,៩៨៩ | ២៧៥,០៩០,៧៦០ |
| ការទូទាត់សងប្រាក់កម្ចី | (៧,២៦៥,៥៥១) | (២៩,១០៥,៧៩៧) | (១២,៩៩៣,១៧៣) | (៥២,១២៨,៦១០) |
| ការទូទាត់សងអនុបំណុល | (១,០០០,០០០) | (៤,០០៦,០០០) | (១,០០០,០០០) | (៤,០១២,០០០) |
| ការទូទាត់សងប្រាក់ដើមភតិសន្យា | (៨៦២,៥១៥) | (៣,៤៥៥,២៣៥) | (៧០៩,០៤៥) | (២,៨៤៤,៦៨៩) |
| **សាច់ប្រាក់សុទ្ធទទួលបានពីសកម្មភាពហិរញ្ញប្បទាន** | **១៦,៩២១,២៩៦** | **៦៧,៧៨៦,៧១២** | **៥៣,៨៦៤,៧៧១** | **២១៦,១០៥,៤៦១** |
| | | | | |
| ការកើនឡើង/(ថយចុះ)សុទ្ធ នូវសាច់ប្រាក់ និងសាច់ប្រាក់សមមូល | (១៤,២៥៧,៩៧៤) | (៥៧,២៧៥,០១៨) | ១៧,២៨០,១៥៩ | ៦៧,៤២០,២២៤ |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល នាដើមគ្រា | ១០៦,៩៧៦,៣២០ | ៤២៩,៨៣០,៨៥៤ | ៧៥,១៧៧,៨០០ | ៣០៣,៤៩២,៧៧៨ |
| លំអៀងពីការប្តូររូបិយប័ណ្ណ | - | (២៩១,៦៧៦) | - | (១,០៨១,១៦៦) |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូល នាចុងគ្រា** | **៩២,៧១៨,៣៤៦** | **៣៧២,២៦៤,១៦០** | **៩២,៤៥៧,៩៥៩** | **៣៦៩,៨៣១,៨៣៦** |

# ផ្នែកទី ៧: ព័ត៌មានអំពីប្រតិបត្តិការជាមួយភាគីជាប់ពាក់ព័ន្ធ

(គិតត្រឹមថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៩)

| ប្រភេទប្រតិបត្តិការ | ប្រតិបត្តិការ |
|---|---|
| ១.ជាមួយភាគហ៊ុនិក | គ្មាន |
| ២.ប្រតិបត្តិការសំខាន់ៗជាមួយអភិបាល ឬបុគ្គលិកជាន់ខ្ពស់ ឬប្រតិបត្តិការ សំខាន់ៗជាមួយបុគ្គលដែលអភិបាល ឬបុគ្គលិកជាន់ខ្ពស់មានផល ប្រយោជន៍ | គ្មាន |
| ៣.ប្រតិបត្តិការសំខាន់ៗជាមួយសមាជិកគ្រួសារផ្ទាល់របស់អភិបាល និង បុគ្គលិកជាន់ខ្ពស់ | គ្មាន |
| ៤.ប្រតិបត្តិការសំខាន់ៗជាមួយបុគ្គលដែលមានទំនាក់ទំនងជាមួយអភិបាលរបស់HKL ក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬ ក្រុមហ៊ុនហូលឌីងរបស់ HKL ដែលទំនាក់ទំនងរបស់បុគ្គលទាំងនោះកើតមាននៅ ក្នុងប្រតិបត្តិការ ឬ ការចាត់ចែងណាមួយដែលធ្វើឡើង ដោយបុគ្គល បោះផ្សាយ | គ្មាន |
| ៥.ប្រតិបត្តិការសំខាន់ៗជាមួយបុគ្គលធ្លាប់ជាអភិបាល ឬបុគ្គលជាប់ពាក់ព័ន្ធជាមួយបុគ្គលធ្លាប់ជាអភិបាល ក្នុងរយៈពេល ០២ (ពីរ) ឆ្នាំ ចុងក្រោយ | គ្មាន |
| ៦.ប្រតិបត្តិការសំខាន់ៗជាមួយអភិបាលដែលទទួលបានផលប្រយោជន៍ ឬកម្រៃវិជ្ជាជីវៈ សម្រាប់សេវាដែល ខ្លួនបានផ្តល់តាមរយៈក្រុមហ៊ុនណាមួយដល់HKL | គ្មាន |
| ៧.ប្រតិបត្តិការសំខាន់ៗជាមួយភាគីជាប់ពាក់ព័ន្ធផ្សេងទៀត | គ្មាន |

## ផ្នែកទី ៨: ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង

ការពិភាក្សា និងការវិភាគខាងក្រោមនេះ គឺជាការពិភាក្សាលើលទ្ធផលនៃប្រតិបត្តិការ និងស្ថានភាពហិរញ្ញវត្ថុ ដោយ គណៈគ្រប់គ្រងរបស់ ហត្ថាកសិករ ដោយផ្អែកទៅលើរបាយការណ៍ហិរញ្ញវត្ថុគិតត្រឹម ថ្ងៃទី៣០ មីនា ឆ្នាំ ២០១៩ ហើយដែលបាន ត្រួតពិនិត្យ ឡើងវិញ ដោយសវនករឯករាជ្យ គិតត្រឹមថ្ងៃទី៣០ មីនា ឆ្នាំ ២០១៩។ របាយការណ៍ហិរញ្ញវត្ថុទាំងនេះរបស់ ហត្ថាកសិករ ត្រូវបានរៀបចំឡើង ដោយអនុលោម ទៅតាមស្តង់ដារ របាយការណ៍ ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ។

គណៈគ្រប់គ្រងធ្វើការពិភាក្សា និងវិភាគលើសមាសធាតុសំខាន់នៃរបាយការណ៍ហិរញ្ញវត្ថុ និងកត្តាសំខាន់ៗ ដែលបាន ជះឥទ្ធិពល ទៅលើប្រាក់ចំណេញរបស់ ហត្ថកសិករតែប៉ុណ្ណោះ ។

### ១-ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ

#### ក-ការវិភាគចំណូល

ហត្ថាកសិករមានចំណូល ២ប្រភេទធំៗគឺ ចំណូលពីការប្រាក់ និងចំណូលផ្សេងៗ

| | |
|---|---|
| **ចំណូលពីការប្រាក់រួមមាន៖** ចំណូលការប្រាក់សុទ្ធដែលទទួលបានពីការផ្តល់ឥណទានដល់ អតិថិជន និងពីការដាក់ប្រាក់បញ្ញើនៅតាមបណ្តា ធនាគារនានា។ ហើយចំណូលទាំងនេះត្រូវទទួលស្គាល់ជាប្រចាំខែ។ | **ចំណូលផ្សេងៗរួមមាន៖** កម្រៃណែនាំ កម្រៃផ្ទេរប្រាក់ចំណូលកម្រៃផ្សេងៗ ចំណូលបាន មកពីការប្រមូលឥណទានលុបចោល ចំណេញពីការប្តូរប្រាក់ ។ល។ |

#### ខ-ការវិភាគចំណូលតាមផ្នែក

ការវិភាគចំណូលតាមផ្នែករបស់ ហត្ថាកសិករមានដូចខាងក្រោម៖

| ល.រ | ប្រភពចំណូល | ត្រីមាសទី១ ឆ្នាំ -២០១៧ | ភាគរយ | ត្រីមាសទី១ ឆ្នាំ -២០១៨ | ភាគរយ | ត្រីមាសទី១ ឆ្នាំសារពើពន្ធបច្ចុប្បន្ន | ភាគរយ |
|---|---|---|---|---|---|---|---|
| | | ចំនួនទឹកប្រាក់ (ពាន់រៀល) | ភាគរយ | ចំនួនទឹកប្រាក់ (លានរៀល) | ភាគរយ | ចំនួនទឹកប្រាក់ (លានរៀល) | ភាគរយ |
| ១ | ចំណូលការប្រាក់ | | | ១០១,៦៧៦ | ៩៦.៩៦ | ១២៧,៤៨៦ | ៩៥.៧៩ |
| ២ | ចំណូលផ្សេងៗ | | | ៣,១៨៧ | ៣.០៤ | ៥,៥៩៩ | ៤.២១ |
| ចំណូលសរុប | | | | ១០៤,៨៦៣ | | ១៣៣,០៨៥ | |

ចំណូលការប្រាក់ ជាចំណូលដ៏ធំនិងសំខាន់សម្រាប់ ហត្ថាកសិករដែលមានរហូលដល់ ៩៥,៧៩% នៃចំណូលសរុប។

### គ-ការវិភាគពីការឡើងចុះនៃថ្លៃវត្ថុធាតុដើម

នាដំណាច់ការិយបរិច្ឆេទថ្ងៃទី ៣០ខែមីនា ឆ្នាំ ២០១៩នេះ គណៈគ្រប់គ្រង់យល់ថា ហត្ថាកសិករ ពុំមានធាតុដែលខុសពីធម្មតាទេ។

### ឃ-ការវិភាគលើពន្ធ

ហត្ថាកសិករ ស្ថិតក្រោមច្បាប់នៃក្រុមហ៊ុនពាណិជ្ជកម្មក្នុងវិស័យពន្ធដារ ដូចនេះ ហត្ថាកសិករ មានភារកិច្ចត្រូវបង់ពន្ធដារទៅតាមច្បាប់និងបញ្ញត្តិជាធរមាន។ ហត្ថាកសិករមានកាតព្វកិច្ចបង់ពន្ធអាករទៅតាមរបបពិត និងសហគ្រាសជាប់ពន្ធធំ ដែលកំណត់ដោយអគ្គនាយកដ្ឋានពន្ធដារ។

### ២-កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ

នាដំណាច់ការិយបរិច្ឆេទថ្ងៃទី ៣០ខែមីនា ឆ្នាំ ២០១៩នេះ គណៈគ្រប់គ្រង់យល់ថា ហត្ថាកសិករ ពុំមានធាតុដែលប៉ះពាល់លើផលចំណេញខុសពីធម្មតាទេ។

### ៣-ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល

នាដំណាច់ការិយបរិច្ឆេទថ្ងៃទី ៣០ខែមីនា ឆ្នាំ ២០១៩នេះ គណៈគ្រប់គ្រង់យល់ថា ហត្ថាកសិករ ពុំមានធាតុដែលជាការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូលខុសពីធម្មតាទេ។

### ៤-ផលប៉ះពាល់នៃការប្តូររូបិយបណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ

ហត្ថាកសិករ បានកត់ត្រាបញ្ជីគណនេយ្យដោយប្រើប្រាស់រូបិយប័ណ្ណគោលគឺ ប្រាក់ដុល្លារ។ ប្រតិបត្តិការជារូបិយប័ណ្ណ ប្រាក់រៀល និងថៃបាត ត្រូវបានប្តូរទៅជា រូបិយប័ណ្ណគោលតាមអត្រាប្តូរប្រាក់នាកាលបរិច្ឆេទ នៃប្រតិបត្តិការនោះ។ ចំណេញ និង ខាតដែលបណ្តាលមកពីការទូទាត់ប្រតិបត្តិការបែបនេះ ការប្តូរ ទ្រព្យសកម្មនិងបំណុលរូបិយប័ណ្ណបរទេស ត្រូវបានកត់ត្រា នៅក្នុងរបាយការណ៍លទ្ធផលលម្អិត។

### ៥-ផលប៉ះពាល់នៃអតិផរណា

ហត្ថាកសិករមិនបានកែប្រែអត្រាការប្រាក់ដោយផ្អែកតាមការប្រែប្រួលនៃអតិផរណាទេ ពោលគឺផ្អែកទៅលើស្ថានភាព ប្រកួតប្រជែងជាក់ស្តែងនៅក្នុងទីផ្សារ។ ហើយនៅតែរក្សា បាននូវចេរភាពហិរញ្ញវត្ថុយ៉ាងល្អ ប្រសើរ។

ហត្ថលេខារបស់អភិបាលហត្ថាកសិករបានឃើញ និងឯកភាព នៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៩។

| | |
|---|---|
| [signature] | [signature] |
| លោក ឡុញ ហៃ<br>សមាជិកឯករាជ្យ | លោក ឌី ដាវុឌ្ឍ<br>សមាជិកឯករាជ្យ |

កាន់តែទុកចិត្ត កាន់តែចំរើន

ហត្ថាកសិករ លីមីតធីត

HATTHA KAKSEKAR LIMITED

**Subsidiary of krungsri bank**

A member of MUFG, a global financial group